

# ករណីសិក្សាទី១

## ការអភិវឌ្ឍន៍ ការផ្គត់ផ្គង់ទឹក ដើម្បីលើកកម្ពស់ជីវភាពមូលដ្ឋានរបស់សហគមន៍ព្រៃឈើ ក្រាំងសេរី ក្នុងខេត្តកំពង់ស្ពឺនៃប្រទេសកម្ពុជា

# ករណីសិក្សា២

## បង្កើនសមត្ថភាពសហគមន៍ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងឃុំសាំង ឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង

កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍( CCBAP ) នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា( UNDP )

SWEDEN

Australian Aid

gef

SGP The GEF Small Grants Programme

UNDP

Empowered lives.
Resilient nations.

# សេចក្តីថ្លែងអំណរគុណ

ការចេញផ្សាយនេះធ្វើទៅបាន តាមរយៈការគាំទ្រដ៏សប្បុរសពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (SIDA) និងទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) តាមរយៈការណែនាំជាយុទ្ធសាស្ត្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក (GEF SGP) និងយោបល់មកពីក្រុមការងារនៃកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍ (CCBAP) ស្ថាប័នទទួលជំនួយពី CCBAP តំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា និងអ្នកទទួលផលនៅកម្រិតសហគមន៍។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះ លោកបណ្ឌិត អឿង ចន្ថា អ្នករៀបចំចងក្រងករណីសិក្សា។

# ករណីសិក្សាទី១

## ការអភិវឌ្ឍន៍ ការផ្គត់ផ្គង់ទឹក ដើម្បីលើកកម្ពស់ជីវភាពមូលដ្ឋាន របស់សហគមន៍ព្រៃឈើ ក្រាំងសេរី ក្នុងខេត្តកំពង់ស្ពឺនៃប្រទេសកម្ពុជា



# មាតិកា


**១. សាវតា និងគោលបំណង** 2

**២. វិធីសាស្រ្ត និងអភិក្រមដែលប្រើប្រាស់ក្នុងគម្រោង** 4

២.១ ការកំណត់តម្រូវការអាទិភាពសម្រាប់សហគមន៍ 4

២.២ ការកសាងអាងស្តុកទឹក និងតំឡើងបណ្តាញទុយោទឹក 5

២.៣ ការបង្កើតគណៈកម្មការគ្រប់គ្រងទឹក និងគ្រប់គ្រងថ្លៃឈ្នួលទឹក 6

២.៤ ការពង្រឹងសមត្ថភាព 7

**៣. សមិទ្ធិផលបឋម និងលទ្ធផល** 8

៣.១ ភាពប្រសើរឡើងនៃសន្តិសុខទឹកដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ 8

៣.២ សមិទ្ធិផលពីវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព 10

៣.៣ កែលម្អជីវភាពរស់នៅ និងជម្រើសផ្សេងៗ 11

៣.៤ ឥទ្ធិពលលើសង្គមនិងបរិស្ថាន 14

៣.៥ ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកសហគមន៍ 16

**៤. បញ្ហាប្រឈមនានា** 17

**៥. ការអនុវត្តល្អៗនិងមេរៀនសម្រាប់ការរៀនសូត្រ** 18

**៦. សន្និដ្ឋាន និងអនុសាសន៍** 19

**៧. ឯកសារយោង** 20

# ១. សារតា និងគោលបំណង

ខេត្តកំពង់ស្ពឺត្រូវបានចាត់ទុកជាតំបន់មួយនៅក្នុងប្រទេសកម្ពុជាដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួតជាញឹកញាប់។ លក្ខណៈជាក់លាក់នៃការប្រែប្រួលអាកាសធាតុក្នុងខេត្តកំពង់ស្ពឺ ត្រូវបានគេសង្កេតឃើញថាមានភាពមិនទៀងទាត់នៃការពន្យាពេលនៃរបបទឹកភ្លៀងនៅដើមរដូវវស្សា ភាពមិនស្មើគ្នានៃបាយទឹកភ្លៀងធ្លាក់ បរិមាណ និងរយៈពេលការផាប់អស់ទឹកភ្លៀងក្នុងរដូវវស្សា ព្រមទាំងកូនរដូវប្រាំង បានកើតឡើងជាញឹកញាប់ក្នុងរយៈពេល២០ឆ្នាំកន្លងទៅពិសេសពីរទៅបីឆ្នាំចុងក្រោយនេះចន្លោះខែកក្កដា-សីហា និងចន្លោះខែតុលា-វិច្ឆិកា[1]។ បញ្ហាទាំងនេះបានបណ្តាលឱ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកសម្រាប់ដំណាំកសិកម្ម និងការប្រើប្រាស់ក្នុងគ្រួសារ។ ក្នុងចំណោមឃុំចំនួន ៤២០ ដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួតកាលពីឆ្នាំ២០០២ កន្លងទៅខេត្តកំពង់ស្ពឺបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ[2]។ កសិករជាច្រើនទទួលស្គាល់ថា គ្រោះរាំងស្ងួតគឺជាកត្តាមួយបានធ្វើអោយប៉ះពាល់ជាអវិជ្ជមានមកលើជីវភាពរស់ នៅរបស់ពួកគេ (រួមមាន សុខភាពចុះខ្សោយ អំពើហឹង្សាក្នុងគ្រួសារ កុមារចូលរៀនមិនទៀតទាត់ បាត់បង់ឱកាសក្នុងការស្វែងរកចំណូល សាមគ្គីភាពក្នុងសហគមន៍ចុះខ្សោយជាពិសេសកង្វះខាតផ្នែក សន្តិសុខស្បៀង។ ហេតុដូច្នេះ កសិករជាច្រើនបានប្រឈមក្នុងការស្វែងរកជម្រើសនានាសម្រាប់ជីវភាពដោយសារបរិស្ថានជុំវិញពុំមានលក្ខណៈអំណោយផលជាមួយធនធានធម្មជាតិ។

ភូមិក្រាំងសេរីជាតំបន់ដែលភាគច្រើនហ៊ុមព័ទ្ធទៅដោយជួរភ្នំស្ថិតនៅក្នុងឃុំគីរីវន្ត ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ភូមិនេះមានគ្រួសារសរុប ៦៧ ដែលមានមនុស្សសរុប ៣៣៥នាក់ (ស្រី១៧៩នាក់)។ មុខរបររបស់អ្នកភូមិរួមមានការធ្វើស្រែ ចំការ កាប់អុស បរបាញ់សត្វ និងប្រមូលផលអនុផលព្រៃឈើ (NTFP)។ ទោះជាយ៉ាងណា ការបរបាញ់សត្វ និងការកាប់ព្រៃឈើត្រូវបានបញ្ឈប់ចាប់តាំងពីការបង្កើតសហគមន៍ព្រៃឈើក្រាំងសេរីដើម្បីគ្រប់គ្រងធនធានធម្មជាតិកាលពីឆ្នាំ២០០៤មកម្ល៉េះ។ សមាជិកសហគមន៍បានរាយការណ៍ថា ជីវភាពរបស់ពួកគាត់ជួបការលំបាកធ្ងន់ធ្ងរដោយសារកង្វះខាតទឹកប្រើប្រាស់សម្រាប់មនុស្ស និងសត្វ ពិសេសនៅរដូវប្រាំង។ ផ្អែកលើរបាយការណ៍ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(VRA) ដែលបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១១ បង្ហាញថា ឃុំក្រាំងសេរីបានទទួលរងផលប៉ះពាល់ដោយសារការកើនឡើងនៃគ្រោះរាំងស្ងួតញឹកញាប់ ហើយរបបទឹកភ្លៀងមិនទៀងទាត់តាំងពីឆ្នាំ១៩៨០។ ឆ្នាំបន្តបន្ទាប់មកទៀត សហគមន៍ទាំងមូល បានប្រឈមមុខនឹងការលំបាកជាច្រើនដោយសារកង្វះខាតទឹកសម្រាប់ការធ្វើកសិកម្ម និងការប្រើប្រាស់ក្នុងគ្រួសារ ដូចជាការចំអិនអាហារ ទឹកងូត ស្រោចស្រពសួនបន្លែ និងការចិញ្ចឹមសត្វ[3]។

ដោយសារទីតាំងភូមិសាស្ត្រហ៊ុមព័ទ្ធទៅដោយភ្នំគីរីវន្ត ការជីកអណ្តូងខួងសម្រាប់ការផ្គត់ផ្គង់ទឹកក្នុងភូមិនៅរដូវប្រាំងមិនទទួលបានជោគជ័យ និងចំណាយខ្ពស់។ អ្នកភូមិខ្លះធ្លាប់បានចំណាយ ពេលជាមធ្យមប្រហែល៤ម៉ោងក្នុងមួយថ្ងៃដើម្បីទៅដងទឹកពីស្រះសាធារណៈដែលស្ថិតនៅចំងាយប្រហែលពី៤ ទៅ ៥ គីឡូម៉ែត្រ សម្រាប់ចំអិនអាហារ និងបរិភោគ។ កុមារជាច្រើនមានភារកិច្ចទៅដងទឹកស្រះ ដែលមានចម្ងាយជិតៗក្នុងភូមិសម្រាប់សត្វ ដូច្នេះពួកគេមិនបានមានពេលគ្រប់គ្រាន់ទៅសាលារៀនឱ្យបានទៀងទាត់នោះទេ។ សមាជិកសហគមន៍ណាដែលពុំមានកំលាំងពលកម្ម និងមធ្យោបាយដឹកជញ្ជូនពួកគេបានទិញទឹកពីភូមិផ្សេងៗដែលមានគេដឹកលក់ ដែលធ្វើអោយបញ្ហាជីវភាពរបស់គាត់កាន់តែលំបាកធ្ងន់ធ្ងរឡើង។ ជាក់ស្តែង ពួកគាត់បានចំណាយ ២ដុល្លារអាមេរិក ដើម្បីទិញទឹក៤០០ លីត្រសម្រាប់ប្រើប្រាស់តែ ១ថ្ងៃ ដែលនេះជា សញ្ញាណមួយបង្ហាញអំពីការលំបាកផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកភូមិខ្លះ ខណៈពេលដែលខ្សែបន្ទាត់ភាពក្រីក្ររបស់ប្រទេសកម្ពុជាគឺ ៣៨៧១ រៀល(តិចជាង១ដុល្លារអាមេរិក)[4] ។ ហេតុដូច្នេះ បញ្ហាប្រឈមចំបងសម្រាប់សហគមន៍ក្រាំងសេរីរួមមានកង្វះខាតទឹកសម្រាប់ដំណាំ ការចិញ្ចឹមសត្វ ជាពិសេសទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ដែលធ្វើអោយ សហគមន៍ប្រឈមមុខនឹងកង្វះខាតស្បៀងអាហារ ជំងឺ និងកង្វះអនាម័យ។ បញ្ហាទាំងនេះបានជះឥទ្ធិពលអវិជ្ជមានមកលើសុខុមាលភាពសហគមន៍ ហើយបានបង្កអោយកុមារតូចៗ ស្ត្រីមេផ្ទះ និងចាស់ជរាងាយនឹងទទួលរងជំងឺដោយសារកង្វះអនាម័យ។ ជាលទ្ធផល ស្រីនិងកុមារមួយចំនួនមានសុខភាព ចុះខ្សោយ (Vong, 2014).។

---

1 NGO Forum. 2012. "Impact of climate change on rice production in Cambodia". NGO Forum on Cambodia: Phnom Penh

2 (NCDM). 2008.

3 VRA Report. 2011. Vulnerability Reduction Assessment in Kraing Serei Community Forestry, Kampong Speu, p.25

4 VONG M. 2014. Paper nominated for Equator Prize 2014. 6p.

ដើម្បីឆ្លើយតបទៅនឹងការប្រឈមទាំងនេះ សហគមន៍ព្រៃឈើក្រាំងសេរី(KCF) ដោយមានការគាំទ្រពីអង្គការម្លប់បៃតង បានស្នើឡើងនូវគម្រោង"ការអភិវឌ្ឍការផ្គត់ផ្គង់ទឹកនិងលើកកម្ពស់ជីវភាពមូលដ្ឋានរបស់សហគមន៍ព្រៃឈើក្រាំងសេរី"។ គោលដៅសំខាន់របស់គម្រោងគឺលើកកម្ពស់ ជីវភាពសមាជិកសហគមន៍មូលដ្ឋានរបស់សហគមន៍ព្រៃឈើក្រាំងសេរី(KCF) ឱ្យបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

គម្រោងនេះមានសកម្មភាពអន្តរាគមន៍ចំនួន៣សំខាន់ៗ៖

១. ជីកអាងស្តុកទឹកទំហំ ៩០ x ៦០ ម៉ែត្រ ជម្រៅ ៤ម៉ែត្រ និងមានទំនប់ស្ទាក់ទឹកនៅផ្នែកខាងក្រោមនៃអាងស្តុកទឹក។
២. តម្លើងប្រព័ន្ធទុយោ (១៦០០ ម៉ែត្រ) ភ្ជាប់ទៅនឹងអាងស្តុកទឹកសម្រាប់៦៧គ្រួសារ ហើយគណៈកម្មការគ្រប់គ្រងទឹកដែលមានលក្ខន្តិកៈច្បាស់លាស់ទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានត្រូវបង្កើតឡើងដើម្បីគ្រប់គ្រង និងថែរក្សាប្រព័ន្ធគ្រប់គ្រងទឹក។
៣. ពង្រឹងសមត្ថភាពសហគមន៍ដើម្បីកែលម្អសកម្មភាពរកប្រាក់ចំណូលតាមរយៈវគ្គបណ្តុះបណ្តាលទៅលើជំនាញបច្ចេកទេសកសិកម្មសមស្រប និងការស្វែងរកទីផ្សារសម្រាប់លក់ផលិតផលក្នុងភូមិ។

គម្រោងនេះទទួលបានមូលនិធិគាំទ្រពីប្រទេសស៊ុយអែត តាមរយៈកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍កម្ពុជា (CCBAP) ដែលគ្រប់គ្រងដោយកម្មវិធីជំនួយខ្នាតតូចរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP Small Grant Programme)។ គម្រោងនេះចាប់ផ្តើមអនុវត្តពីខែធ្នូ ឆ្នាំ២០១១ រហូតដល់ ខែវិច្ឆិកា ឆ្នាំ២០១២ ដោយមានមូលនិធិសរុប៦០,២៥៧ ដុល្លារអាមេរិក (គាំទ្រពីកម្មវិធីជំនួយខ្នាតតូចរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិចំនួន ៤៩,៨៣២ ដុល្លារអាមេរិក បដិភាគថវិកាពីអង្គការទស្សនៈពិភពលោកកម្ពុជាចំនួន ៥,៧០០ ដុល្លារអាមេរិក និងការចូលរួមបដិភាគពីសហគមន៍ដោយគិតជាទឹកប្រាក់ចំនួន ៤,២២៥ដុល្លារអាមេរិក (ដីសម្រាប់ធ្វើអាងទឹកកំលាំងពលកម្ម, និងថវិកាចំនួន៥០០ដុល្លារអាមេរិកពី ឯកឧត្តម រ័ត្ន សុវណ្ណារ៉ា នាយខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកំពង់ស្ពឺ)។



# ២. វិធីសាស្ត្រ និងអភិក្រមដែលប្រើប្រាស់ក្នុងគម្រោង

## ២.១ ការកំណត់តម្រូវការអាទិភាពសម្រាប់សហគមន៍

សមាជិកសហគមន៍ព្រៃឈើក្រាំងសេរីបានទទួលការជូនដំណឹងអំពីចំណេះដឹងនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វាលើសហគមន៍។ បន្ទាប់មក សហគមន៍ព្រៃឈើក្រាំងសេរីបានធ្វើការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(VRA) ដោយមានកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរឃុំដើម្បីកំណត់ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងតម្រូវការអាទិភាព(រូបថត១)។ ដើម្បីបន្សាំជាមួយបញ្ហាប្រឈមនានាដែលពួកគាត់ជួបប្រទះនៅក្នុងសហគមន៍ ពួកគាត់បានលើកឡើងថាសកម្មភាព អាទិភាពដែលត្រូវធ្វើរួមមានការកសាងអាងស្តុកទឹក ការពង្រឹងសមត្ថភាពរបស់គណៈកម្មការគ្រប់គ្រងទឹកដើម្បីគ្រប់គ្រងអាងស្តុកទឹក និងបណ្តាញទុយយោទឹក ពង្រឹងចំណេះដឹងទៅលើការប្រែប្រួលអាកាសធាតុ បង្កើនការគាំទ្របន្ថែមចំពោះក្រុមសន្សំប្រាក់ កែលម្អការដាំកូនឈើ និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដែលមានភាពធន់ទៅនឹងភាពរាំងស្ងួត និងការចិញ្ចឹមសត្វដើម្បីផ្គត់ផ្គង់ជីវភាពដែលបានមកពីសកម្មភាពបរចិញ្ចឹមជីវិតផ្សេងៗគ្នា។



រូបភាព១: ការប្រជុំរបស់សហគមន៍ដើម្បីវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(*VRA*)

# ២.២ ការកសាងអាងស្តុកទឹក និងដំឡើងបណ្តាញទុយោទឹក

តំបន់ប៉ែកខាងលើនៃភូមិចំងាយប្រហែល ១គ.ម ជាទីតាំងដែលមានសក្តានុពលសម្រាប់ជីកអាងស្តុកទឹក ដែលមានកម្រិតកម្ពស់ ៩៤ ម៉ែត្រធៀបទៅនឹងកម្រិតនីវ៉ូទឹកសមុទ្រ។ ប្រភពទឹកទាំងនោះបានហូរចេញពីតំបន់ទីជម្រាលជើងភ្នំដែលមានផ្ទៃដីប្រហែល ១៥ហិកតា ចូលទៅក្នុងអាងស្តុកទឹក និងបានបំពេញទឹកអាងនោះអំឡុងពេលរដូវវស្សា។ នៅជំហានទី១ អាងស្តុកទឹកមួយត្រូវបានជីកទំហំ បណ្តោយ៩០ម៉ែត្រ x ទទឹង៦០ម៉ែត្រ x ជម្រៅ ៤ម៉ែត្រ។ ហើយបន្ទាប់មក អាងស្តុកទឹកនេះបានពង្រីកទំហំបន្ថែមបណ្តោយ៥០ម៉ែត្រ x ទទឹង៣០ម៉ែត្រ x ជម្រៅ ៣ម៉ែត្រ ដែលមានគុណភាពខ្ពស់ (រូបថត២)។ ដូច្នេះ បរិមាណទឹកសរុបចំនួន ២៥០០០ ម៉ែត្រគូប ត្រូវបានស្តុកទុកក្នុងអាង។

លើសពីនេះទៅទៀត ទំនប់ដែលព័ទ្ធជុំវិញអាងស្តុកទឹកក៏បានសាងសង់ឡើងដែលមានប្រវែង ២៥០ម៉ែត្រ បាទក្រោម ១០ម៉ែត្រ ខ្នងលើ៤ម៉ែត្រ និងកំពស់៤ម៉ែត្រ។ ប្រព័ន្ធដោះទឹកក៏ត្រូវបានសាងសង់ឡើងដើម្បីការពារពេលដែលទឹកហៀរចេញពីអាងស្តុកទឹកផងដែរ។ ការសាងសង់នេះ ត្រូវបានទទួលការគាំទ្រពីមន្ត្រីបច្ចេកទេសមកពីមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ស្ពឺ។

ទុយោមេមួយដែលមានប្រវែង២៨៩២ម៉ែត្រត្រូវបានតម្លើងដើម្បីនាំយកទឹកពីអាងស្តុកទឹកទៅភូមិ។ ការតភ្ជាប់បណ្តាញនេះត្រូវបានតម្លើងទុយោមេជា៤ដំណាក់កាលសំខាន់ៗ:

- (ដំណាក់កាលទី១៖ ប្រវែង៤៤០ ម៉ែត្រ ដោយមានទំហំមុខកាត់ ១៥០ មីលីម៉ែត្រ
- ដំណាក់កាលទី២៖ ប្រវែង៤៤០ម៉ែត្រ ដោយមានទំហំមុខកាត់ ១០០ មីលីម៉ែត្រ
- ដំណាក់កាលទី៣៖ ប្រវែង២៨៨ម៉ែត្រ ដោយមានទំហំមុខកាត់ ៨០ មីលីម៉ែត្រ, និង
- ដំណាក់កាលទី៤៖ ប្រវែង១៧២៤ម៉ែត្រ ដោយមានទំហំមុខកាត់ ៤៩ មីលីម៉ែត្រ) (រូបថត៣)។
- ទុយោត្រូវបានតម្លើងដោយប្រើប្រាស់ ឧបករណ៍ឋានលេខាដើម្បីស្ទង់កម្រិតកម្ពស់ដី ដោយមានជំនួយបច្ចេកទេស ពីមន្ត្រីបច្ចេកទេសនៃមន្ទីរធនធានទឹក និងឧតុនិយម (PDOWRAM)។



រូបភាព២: ការកសាងអាងស្តុកទឹកដើម្បីគាំទ្រដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកសហគមន៍



រូបថត៣: សកម្មភាពចូលរួមកំលាំងពលកម្មដើម្បីតម្លើងបណ្តាញទុយោទឹកពីអាងស្តុកទឹកទៅតំបន់លំនៅដ្ឋានក្នុងភូមិក្រាំងសេរី

## ២.៣ ការបង្កើតគណៈកម្មការគ្រប់គ្រងទឹក និងគ្រប់គ្រងថ្លៃឈ្នួលទឹក

គណៈកម្មការគ្រប់គ្រងទឹកនិងអនុគណៈកម្មការត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតគាំទ្រពីសមាជិកសហគមន៍និងសហគមន៍ព្រៃឈើតាំងពីឆ្នាំ២០១២(រូបថត៤)។ សមាជិកគណៈកម្មការគ្រប់គ្រងទឹកមាន០៧នាក់(ស្ត្រី០១រូប) និង ៥នាក់ (ស្ត្រី០២នាក់)សម្រាប់អនុគណៈកម្មការ។ ប្រធានគណៈកម្មការទទួលខុសត្រូវលើការងារគ្រប់គ្រងទូទៅពិសេសការងារថវិកា ចំណែកសមាជិកផ្សេងទទួលបន្ទុកលើការប្រមូលថ្លៃទឹក ប្រតិបត្តិការ និងថែទាំ។ តួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងបង្ហាញដូចខាងក្រោម៖

ប្រធានគណៈកម្មការ
អនុប្រធានគណៈកម្មការ

- ទទួលខុសត្រូវលើការងារគ្រប់គ្រងទូទៅនិងសម្របសម្រួល
- ផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុ
- ប្រជុំ និងទំនាក់ទំនង
- ដោះស្រាយទំនាស់

អនុគណៈកម្មការ

- ប្រមូលថ្លៃទឹក
- ប្រតិបត្តិការ និងថែទាំ

គណៈកម្មការបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាការគ្រប់គ្រងនិងថែរក្សាអាងស្តុកទឹក និងប្រព័ន្ធទុយោទឹករួមបញ្ចូលទាំងនាឡិកាស្ទង់ទឹកទាំងអំឡុងពេលអនុវត្ត និងបញ្ចប់គម្រោង។ គណៈកម្មការក៏ធានាឱ្យមានភាពស្មើគ្នានៃការបែងចែកទឹកទៅដល់សមាជិកសហគមន៍ និងនិរន្តរភាពនៃការប្រើប្រាស់ទឹកពេញមួយឆ្នាំ។ ពួកគាត់បានបង្កើតបទបញ្ញត្តិសម្រាប់ការប្រើប្រាស់ទឹកដែលមាន៨ជំពូក និង២០មាត្រា។ នៅក្នុងបទបញ្ញត្តិនេះរួមបញ្ចូលទាំង ប្រតិបត្តិការអាងស្តុកទឹក ការត្រួតពិនិត្យបណ្តាញទុយោទឹក និងការប្រមូលថ្លៃទឹកពីក្រុមទទួលផលគម្រោង។ តម្លៃប្រើប្រាស់ទឹក(៥០០រៀល/ម៉ែត្រគូប) បានប្រមូលទុកក្នុងកញ្ចប់មូលនិធិរបស់គណៈកម្មការសម្រាប់ប្រើប្រាស់សំខាន់លើការថែទាំបណ្តាញទុយោទឹក និងសកម្មភាពអភិវឌ្ឍន៍សហគមន៍ដទៃទៀត។




រូបភាព៤: ការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងទឹក

# ២.៤ ការពង្រឹងសមត្ថភាព

គម្រោងបានផ្តល់ការពង្រឹងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងទឹក និងសមាជិកសហគមន៍តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលលើហិរញ្ញវត្ថុ និងការសរសេរបាយការណ៍ដែលធ្វើអោយពួកគាត់អាចអនុវត្តតួនាទីរបស់គាត់ដោយការទទួលខុសត្រូវ។ ពួកគាត់ក៏ទទួលបានការពង្រឹងសមត្ថភាពលើការប្រើប្រាស់ទឹកផងដែរ (រូបថត៥)។ លើសពីនេះទៅទៀតវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្ម (ការចិញ្ចឹមត្រី និងបន្លែ) និងការចិញ្ចឹមសត្វក៏បានផ្តល់ជូនដល់ប្រជាជនក្នុងភូមិអំឡុងពេលអនុវត្តន៍គម្រោងផងដែរ។



រូបថត៥: សហគមន៍ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងការផ្គត់ផ្គង់ទឹក

# ៣. សមិទ្ធផលបឋម និងលទ្ធផល

## ៣.១ ភាពប្រសើរឡើងនៃសន្តិសុខទឹកដើម្បីបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ

អំឡុងពេលរដូវវស្សា ទឹកមិនមែនជាបញ្ហាចំបងសម្រាប់ការប្រើប្រាស់នៅក្នុងគ្រួសារ ការដាំដំណាំ និងការចិញ្ចឹមសត្វទេ ពីព្រោះជាទូទៅពួកគាត់មានទឹកភ្លៀងប្រើប្រាស់គ្រប់គ្រាន់។ ទោះបីយ៉ាងណាក៏ដោយ កង្វះខាតទឹកសម្រាប់ប្រើប្រាស់ទាំងក្នុងគ្រួសារ និងការដាំដុះដំណាំតាមផ្ទះនៅតែជាឧបសគ្គសម្រាប់ សហគមន៍ក្រាំងសេរី ជាពិសេសនៅក្នុងរដូវប្រាំង។ ការជីកអាងស្តុកទឹកដែលមានសមត្ថភាពស្តុកទឹកបាន ២៥,០០០ម៉ែត្រគូប បានផ្តល់នូវក្តីសង្ឃឹមថ្មីមួយសម្រាប់សហគមន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាលំបាកដែលបានកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ(រូបភាព៦)។ នៅរដូវវស្សា ទឹកបានហូរចេញពីតំបន់ទីជម្រាលដែលមានផ្ទៃដីប្រមាណ១៥ហិកតាចូលទៅក្នុងអាងស្តុកទឹកនេះហើយជាទូទៅទឹកអាងពេញនៅក្នុងខែកញ្ញា។ ហេតុដូច្នេះ សហគមន៍អាចមានទឹកច្រើន និងគ្រប់គ្រាន់ជាងមុននៅក្នុងរដូវប្រាំង ជាពិសេសនៅពេលដែលភ្លៀងធ្លាក់មិនទៀងទាត់ មានការអូសបន្លាយនៃការរាំងស្ងួតនាំឱ្យ ស្រះធម្មជាតិជិតៗនោះ មានទឹកតិចតួចដែលមិនអាចផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់សហគមន៍ប្រើប្រាស់។ ចំពោះសមត្ថភាពស្តុកទឹកក្នុងពេលសាងសង់អាងស្តុកទឹកថ្មីដំបូង គឺគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់សហគមន៍ព្រៃឈើក្រាំងសេរីចំនួន៦៧គ្រួសារ ដោយគ្មានឧបសគ្គណាមួយដូចពេលមុនគម្រោងចាប់ផ្តើមអនុវត្តនោះទេ។



រូបភាព៦: ទឹកនៅក្នុងអាងដែលទើបសាងសង់ហើយ សម្រាប់ការផ្គត់ផ្គង់សហគមន៍

បន្ទាប់ពីការជីកអាងស្តុកទឹក ទឹកត្រូវបានបង្ហូរតាមបំពង់ទុយោទៅកាន់ទីតាំងលំនៅដ្ឋានរបស់សហគមន៍ ដែលមានចំងាយប្រហែលជា ៩០០ម៉ែត្រ និងមានរយៈកម្ពស់ចន្លោះ ពី ៧៤ម៉ែត្រ ទៅ ៨២ម៉ែត្រ ធៀបទៅនឹងនីវ៉ូទឹកសមុទ្រ។ (ទីតាំងលំនៅដ្ឋានមាននីវ៉ូទាបជាងទីតាំងអាងស្តុកទឹក ពី១២ម៉ែត្រ ទៅ២០ម៉ែត្រ) ដែលអ្នកភូមិអាចតភ្ជាប់បណ្តាញទុយោទឹកទៅដល់ផ្ទះរបស់គាត់ដោយងាយស្រួល។ គ្រប់គ្រួសារនៅក្នុងសហគមន៍ទាំងមូលបានតភ្ជាប់បណ្តាញទឹក ដល់ផ្ទះ ដោយមានការចូលរួមចេញថ្លៃតភ្ជាប់ទុយោទឹកពីបណ្តាញបំពង់ទឹកមេចូលទៅតាមផ្ទះនីមួយៗ (សម្រាប់ទុយោចូលតាមផ្ទះនិងកុងទ័រទឹក)។ អ្នកភូមិមានសេចក្តីសប្បាយរីករាយជាខ្លាំងនៅពេលដែលប្រព័ន្ធផ្គត់ផ្គង់ទឹករបស់សហគមន៍ត្រូវបានតភ្ជាប់តាមផ្ទះ (រូបភាព៧)។ ពួកគាត់មិនចាំបាច់ចំណាយពេលទៅដឹកជញ្ជូនទឹកពី ៣ ទៅ៤ម៉ោងក្នុងមួយថ្ងៃ និងទិញទឹកពីភូមិផ្សេងៗដូចពីមុនទៀតនោះទេ។ សម្រាប់ឆ្នាំទី១ គ្រួសារនីមួយៗត្រូវបានកំណត់កម្រិតប្រើប្រាស់ទឹកត្រឹមតែ ១៥ម$^{៣}$/ខែប៉ុណ្ណោះ។ បច្ចុប្បន្ន សហគមន៍ទាំងមូលបានប្រើប្រាស់ទឹកប្រមាណជា ១០០០ម$^{៣}$/ខែ។ ដូច្នេះ បរិមាណទឹកនៅក្នុងអាងនេះច្រើនជាងតម្រូវការទឹកសម្រាប់ការប្រើប្រាស់ក្នុងរដូវប្រាំងលើសពី៦ខែ(៦០០០ម$^{៣}$) បើប្រៀបធៀបទៅនឹងសមត្ថភាពស្តុកនៅក្នុងអាងដែលមានទឹកចំនួន ២៥០០០ម$^{៣}$។ ដូច្នេះ ទឹកដែលនៅសល់ក្នុងអាងស្តុកទឹកអាចប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ រួមទាំងការពង្រីកបណ្តាញចែកចាយទឹកទៅភូមិផ្សេងៗដែលស្ថិតនៅជិតខាង។ ជាលទ្ធផល អាងស្តុកទឹកនេះមានសមត្ថភាពអាចពង្រីកប្រព័ន្ធទឹករហូតទៅដល់២ភូមិដែលស្ថិតនៅក្បែរៗនោះ គ្រួសារចំនួន២០នៅក្នុងភូមិកន្ទួតជ្រុំនៅក្នុងឆ្នាំ២០១៣ និង៣៩គ្រួសារនៅក្នុងភូមិប្រកបារ នៅដើមឆ្នាំ២០១៥ ។





រូបភាព៧: គ្រួសារសហគមន៍ទទួលបានការផ្គត់ផ្គង់ទឹកពីបណ្តាញទុយោ

# ៣.២ សមិទ្ធិផលពីវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព

បន្ទាប់ពីការផ្តល់វគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រប់ប្រព័ន្ធផ្គត់ផ្គង់ទឹក មូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំរបាយការណ៍ អនុគណៈកម្មការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកត្រូវបានបង្កើតឡើង និងមានតួនាទីច្បាស់លាស់ (រូបថត៨)។ អនុគណៈកម្មការមានបទបញ្ញត្តិរបស់ខ្លួនដែលបានបង្កើតឡើងដោយមានការចូលរួមពីតំណាងគ្រួសារនីមួយៗក្នុងភូមិ។ វគ្គបណ្តុះបណ្តាលផ្សេងៗទៀតដូចជា បច្ចេកទេសសួនបន្លែ បច្ចេកទេសចិញ្ចឹមសត្វ និងជំនាញអាជីវកម្មខ្នាតតូចក៏ត្រូវបានផ្តល់ជូនផងដែរទៅសមាជិកចំនួន២៨នាក់ សម្រាប់រយៈពេល២ ថ្ងៃក្នុងគោលបំណងដើម្បីជួយពួកគាត់ក្នុងការកែលម្អ សកម្មភាពជម្រើសអាជីវកម្ម។

សហគមន៍បានរាយការណ៍ថា បន្ទាប់ពីគម្រោងបានបញ្ចប់នៅចុងឆ្នាំ២០១២ មានគ្រួសារជាច្រើននៅបន្តការធ្វើសួនបន្លែ និងការចិញ្ចឹមសត្វសម្រាប់ការផ្គត់ផ្គង់ជីវភាពរស់នៅ និងនៅសល់សម្រាប់លក់ទៅទីផ្សាររកចំណូល។ ជាការកត់សំគាល់ បង្ហាញឱ្យឃើញថាចំណេះដឹងដែលបានផ្តល់ឱ្យសហគមន៍បានជួយពួកគាត់ដើម្បីគ្រប់គ្រង និងកែលម្អ ជីវភាពរស់នៅរបស់ពួកគាត់ដើម្បីឆ្លើយតបទៅនឹងផលលំបាកនានាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ។



រូបភាព៨: វគ្គបណ្តុះបណ្តាលផ្តល់ឱ្យសមាជិកសហគមន៍នៅក្នុងសហគមន៍ព្រៃឈើក្រាំងសេរី

# ៣.៣ កែលម្អជីវភាពរស់នៅ និងជម្រើសផ្សេងៗ

សហគមន៍ព្រៃឈើក្រាំងសេរីទទួលស្គាល់ថា ពិតជាមានការលំបាកខ្លាំងមែនទែនក្នុងការស្វែងរកទឹកសម្រាប់ប្រើប្រាស់ទាំងមនុស្ស និងសត្វមុនពេលគម្រោងចាប់ផ្តើម។ សមាជិកសហគមន៍បានចំណាយពេលពេញមួយយប់នៅតំបន់ឆ្ងាយពីភូមិដើម្បីប្រមូលទឹកចេញពីក្រោមដីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ពេលខ្លះ បញ្ហានេះបាននាំឱ្យមានជម្លោះ និងអំពើហឹង្សាក្នុងចំណោមប្រជាជនដែលកំពុងស្វែងរកទឹក ហើយក៏កើតមានឡើងនូវអំពើហឹង្សាក្នុងគ្រួសារផងដែរ។ ការលំបាកក្នុងការស្វែងរកទឹកមានន័យថាប្រជាជនបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីស្វែងរកទឹកសម្រាប់បំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ពួកគាត់។ ហេតុដូចនេះ បញ្ហានេះបានធ្វើឱ្យអ្នកភូមិបាត់ឱកាសក្នុងការអនុវត្តសកម្មភាពស្វែងរកប្រាក់ចំណូល។ ការផ្គត់ផ្គង់ទឹកពីអាងស្តុក មិនត្រឹមតែសម្រាប់ប្រើប្រាស់ក្នុងគ្រួសាររបស់សហគមន៍ព្រៃឈើក្រាំងសេរីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចប្រើប្រាស់សម្រាប់ការដាំដុះ និងការចិញ្ចឹមសត្វផងដែរ។ មុនពេលគម្រោងអនុវត្ត សហគមន៍ពុំមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននោះទេ ដែលនេះគឺជាបញ្ហាប្រឈមដ៏ធំចំពោះជម្រើសនានាដើម្បីកែលម្អជីវភាពរស់នៅ។ ប្រសិនបើពួកគាត់ត្រូវទិញទឹកប្រើប្រាស់ប្រចាំខែ ពួកគាត់នឹងចំណាយថវិកាកាន់តែច្រើនឡើងដែលបានបង្កើនបន្ទុកបន្ថែមទៀតលើបញ្ហាហិរញ្ញវត្ថុរបស់គាត់។ ចាប់តាំងពីគម្រោងអនុវត្តន៍មក អ្នកភូមិមិនចាំបាច់ចំណាយលុយច្រើនសម្រាប់ទិញ និងដឹកជញ្ជូនទឹកពីកន្លែងផ្សេងៗនោះទេ។ ជាធម្មតា ពួកគាត់បានចំណាយ២ដុល្លារអាមេរិកដើម្បីទិញទឹក៤០០លីត្រសម្រាប់ប្រើប្រាស់ក្នុងមួយថ្ងៃប៉ុណ្ណោះ។ ផ្អែកលើបទបញ្ញត្តិដែលគណៈកម្មការគ្រប់គ្រងទឹកបានបង្កើតឡើង អ្នកភូមិ ក្រាំងសេរីចំណាយត្រឹមតែ៥០០រៀល(០.១២៥ ដុល្លារអាមេរិក) សម្រាប់ទិញទឹក១ម៉ែត្រគូប ហើយគ្រួសារនីមួយៗអាចប្រើប្រាស់អតិបរមា ១៥ម៉ែត្រគូប/ខែ។ ដូច្នេះ ពួកគាត់ចាំបាច់ត្រូវចំណាយត្រឹមតែ១.៨៧៥ ដុល្លារអាមេរិក/ខែ ដើម្បីទិញទឹក១៥ម៉ែត្រគូប។ កាលពីមុន ប្រមាណជា១០គ្រួសារបានទិញទឹកពីភូមិក្បែរៗនោះក្នុងរយៈពេល៣ខែ នៅពេលដែលពុំមានភ្លៀងធ្លាក់ ឬពុំមានប្រភពទឹក, ពួកគាត់ត្រូវចំនាយថវិកាច្រើន ( ៥ដុល្លារ/ម៉ែត្រគូប)។ ៥០ ទៅ ៦០គ្រួសារបានដឹកជញ្ជូនទឹកដោយខ្លួនឯង ហើយពួកគាត់ចំណាយយ៉ាងហោចណាស់ ១០ដុល្លារ/ខែសម្រាប់ថ្លៃសាំងម៉ូតូ។ បច្ចុប្បន្ន ភាគច្រើននៃពួកគាត់ចំណាយថវិកាតិចជាង២,៥ដុល្លារអាមេរិក/ខែសម្រាប់ថ្លៃទឹកនៅក្នុងរដូវប្រាំង។ គ្រួសារខ្លះដែលធ្លាប់តែទិញទឹកអំឡុងពេលរដូវប្រាំង អាចសន្សំសំចៃប្រាក់រហូតដល់៥៨ដុល្លារក្នុង១ខែ( តារាងទី១ )។

តារាងទី១: ថវិកាចំណាយក្នុងគ្រួសារមួយសម្រាប់ថ្លៃទឹកមុនពេល និងក្រោយពេលអនុវត្តន៍គម្រោង

| ការប្រើប្រាស់ទឹកក្នុងរដូវប្រាំង | ពីមុន | | ក្រោយមក | | សំគាល់ |
|---|---|---|---|---|---|
| | ឯកតា(ម$^{៣}$) | តម្លៃ(USD) | ឯកតា(ម$^{៣}$) | តម្លៃ(USD) | ប្រជាជនអាចសន្សំប្រាក់បានចំនួន ៥៨ដុល្លារ/ខែ |
| ក្នុង១ឯកតា | ១ | ៥.០០ | ១ | ០.១២៥ | |
| ក្នុង១ថ្ងៃ | ០.៤ | ២.០០ | ០.៥ | ០.០៦២៥ | |
| ក្នុង១ខែ | ១២ | ៦០.០០ | ១៥ | ១.៨៧៥ | |

ដូច្នេះ គម្រោងនេះបានបង្ហាញលទ្ធផលគួរឱ្យកត់សំគាល់ក្នុងការកែលម្អជីវភាពនៅក្នុងសហគមន៍ក្រាំងសេរី ពិសេសសហគមន៍ទាំងមូលសរុប៦៧គ្រួសារ អាចសន្សំសំចៃប្រាក់ចន្លោះ ១០០០ ទៅ ១៥០០ដុល្លារ/ខែ (៦០០០ ទៅ ៩០០០ ដុល្លារ សម្រាប់រយៈពេល៦ខែក្នុងរដូវប្រាំង) ដែលបានចំណាយលើបញ្ហាទឹកប្រើប្រាស់។ លើសពីនេះទៅទៀត គេសង្កេតឃើញថា គម្រោងនេះបានជួយដល់អ្នកភូមិដែលរស់នៅជិតខាងសរុប ២០គ្រួសារ អាចទទួលបានការផ្គត់ផ្គង់ទឹកដោយបានតភ្ជាប់ទុយោតាមផ្ទះ បន្ទាប់ពីឆ្នាំទី២នៃគម្រោងដែលបានបញ្ចប់។ ដូច្នេះ បច្ចុប្បន្នមាន៨៧គ្រួសារដែលបានទទួលផលប្រយោជន៍ពីគម្រោងនេះ។

តាំងពីគម្រោងចូលមកដល់ ប្រជាជនរស់នៅភូមិក្រាំងសេរីមិនចាំបាច់ស្វែងរកទឹកពីទីកន្លែងឆ្ងាយទៀតទេ។ គម្រោងនេះបានជួយពួកគាត់ចំណេញពេលវេលាជាច្រើន និងអាចឱ្យពួកគាត់ត្រឡប់មកផ្តោតលើសកម្មភាពកែលម្អជីវភាពវិញ។ ជាការសង្កេតឃើញថា គ្រួសារមួយចំនួនបានចាប់ផ្តើមដាំដុះបន្លែ និងដំណាំជិតៗផ្ទះ ព្រមទាំងមានការចិញ្ចឹមសត្វផងដែរ (រូបភាព៩)។ ជាលទ្ធផល ច្រើនជាង៥០ភាគរយ



បានប្រើប្រាស់ទឹកសម្រាប់សួនបន្លែ និងប្រហែល៣០ភាគរយ ប្រើប្រាស់សម្រាប់ការចិញ្ចឹមសត្វ។ សកម្មភាពរកប្រាក់ចំណូលទាំងនេះពិតជាជួយពួកគាត់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពបន្សុំាក្នុងការឆ្លើយតបទៅនឹងផលលំបាកនៃគ្រោះរាំងស្ងួតដែលបានកើតឡើងនៅក្នុងសហគមន៍ទាំងក្នុងរដូវវស្សា និងរដូវប្រាំង។

គម្រោងនេះក៏បានផ្តល់ស្រះទឹកចំនួន៣ ទៅសហគមន៍ព្រៃឈើក្រាំងសេរីផងដែរដើម្បីកែលម្អជីវភាពតាមរយៈការចិញ្ចឹមត្រី និងការស្តុកទឹកភ្លៀងសម្រាប់ការដាំដុះបន្លែនៅដើមរដូវប្រាំងក្នុង ខែវិច្ឆិកា (រូបភាព១០)។ ឥទ្ធិពលពីការចិញ្ចឹមត្រីក៏បានចូលរួមក្នុងការបង្កើនសមត្ថភាពបន្សុំារបស់កសិករកាន់តែខ្លាំងផងដែរសម្រាប់ជម្រើសមុខរបរដើម្បីធានាសន្តិសុខស្បៀង។ បន្ទាប់ពីការប្រមូលផលត្រី អ្នកភូមិក៏អាចប្រើប្រាស់ទឹកសម្រាប់ដាំដុះ បន្លែចាប់ពីខែវិច្ឆិកាតទៅមុខ។



រូបភាព៩ : កែលម្អការដាំដុះដំណាំ និងការចិញ្ចឹមសត្វដោយប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹករបស់សហគមន៍



រូបភាព១០: ស្រះសហគមន៍សម្រាប់ចិញ្ចឹមត្រី និងស្រោចស្រពបន្លែ

លើសពីនេះទៅទៀត គម្រោងក៏បានគាំទ្រសមាជិកសហគមន៍លើការកែលម្អក្រុមសន្សំប្រាក់ ដែលមានស្រាប់ផងដែរ។ ក្រុមនីមួយៗបានទទួលទុនចាប់ផ្ដើមចំនួន៥០០ដុល្លារ។ សមាជិកក្រុមបានដាក់ប្រាក់សន្សំរបស់គាត់ចន្លោះពី២.៥ ដុល្លារ ទៅ៧.៥ដុល្លារក្នុងមួយខែ។ ដូច្នេះ ពួកគាត់អាចត្រៀមបម្រុងទុកថវិកាក្នុងករណីបន្ទាន់ និងកម្ចីដែលមានការប្រាក់ទាបសម្រាប់ការចាប់ផ្ដើមអាជីវកម្មខ្នាតតូច ទិញសម្ភារៈកសិកម្ម និងចំណាយលើការថែទាំសុខភាព។ សមាជិកសហគមន៍បានឯកភាពថាក្រុមសន្សំប្រាក់គឺជាប្រភពកម្ចីដ៏ងាយស្រួលដែលមានការប្រាក់សមរម្យដែលអាចផ្ដល់ដល់ពួកគាត់នូវការគាំទ្របន្ថែមអំឡុងពេលគ្រោះមហន្តរាយធម្មជាតិ ពិសេសការអូសបន្លាយរយៈពេលរាំងស្ងួតពីការប្រែប្រួលអាកាសធាតុ។ រហូតដល់ឆ្នាំ២០១៥ ការសន្សំប្រាក់ក្នុងក្រុមទាំង៤ បានកើនឡើងដូចដែលបានបង្ហាញនៅក្នុងតារាងទី២។ បើគ្មានក្រុមសន្សំប្រាក់ សមាជិកសហគមន៍នឹងស្វែងរកប្រាក់កម្ចីពីស្ថាប័នឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមូលដ្ឋានដែលមានអត្រាការប្រាក់ខ្ពស់។ ជាការសង្កេតឃើញថាមានការកើនឡើងនៃការខ្ចីប្រាក់ពីក្រុមសន្សំប្រាក់ដើម្បីចំណាយលើសកម្មភាពកែលម្អជីវភាព (១៩% ប្រើប្រាស់ជាទុនសម្រាប់អាជីវកម្ម ១៣% សម្រាប់ការចិញ្ចឹមសត្វ ៤៣% ប្រើប្រាស់សម្រាប់ទិញសម្ភារៈកសិកម្ម ២៨% សម្រាប់ថែទាំសុខភាព និង១៤%សម្រាប់បញ្ជូនកូនទៅសាលារៀន[5]។

តារាង២: មូលនិធិសន្សំពីក្រុមទាំងបួននៅក្នុងសហគមន៍ក្រាំងសេរី

| ក្រុមសន្សំ | កាលបរិច្ឆេទបង្កើត | មូលនិធិចាប់ផ្ដើម | សរុបមូលនិធិសន្សំ នៅពេលបច្ចុប្បន្ន (ខែកុម្ភៈ ឆ្នាំ២០១៥) | |
|---|---|---|---|---|
| | | គាំទ្រដោយគម្រោង(USD) | មូលនិធិសន្សំដោយសហគមន៍(USD) | មូលនិធិគម្រោង និងការសន្សំដោយសហគមន៍ |
| ក្រុមទី១ | មករា ២០១២ | ៥០០ | ៨៧៥ | ១៧៥០ |
| ក្រុមទី២ | មករា ២០១២ | ៥០០ | ១១២៥ | ៣៥០០ |
| ក្រុមទី៣ | មករា ២០១២ | ៥០០ | ៧៥០ | ១៦២៥ |
| ក្រុមទី៤ | មករា ២០១២ | ៥០០ | ៧៥០ | ១៦២៥ |

5 Evaluation Report. 2012. Water Supply System Development and Livelihood Improvement (WSSDLI) for Krang Serei Community Forestry Members, p.24.

# ៣.៤ ឥទ្ធិពលលើសង្គម និងបរិស្ថាន



រូបភាព១២: កុមារក្នុងសហគមន៍បានចូលរៀននៅសាលា

https://lyrathana.files.wordpress.com/2013/06/phaao_schoolkids-e1278578741873.jpg

ចាប់តាំងពីគម្រោងត្រូវបានអនុវត្ត សហគមន៍មានការផ្លាស់ប្តូរគួរឱ្យកត់សំគាល់ មិនត្រឹមតែកែលម្អជីវភាពរស់នៅតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែលម្អបញ្ហាសង្គម និងបរិស្ថានផងដែរ។ មុនពេលអនុវត្តគម្រោងសហគមន៍នេះមានបញ្ហាមួយចំនួនដូចជា អំពើហឹង្សាក្នុងគ្រួសារ សុខភាពទ្រុឌទ្រោម កុមារទៅសាលាមិនទៀងទាត់ និងចំណាយពេលច្រើនក្នុងការទៅរកទឹក។



រូបភាព១១: ការទទួលបានបង្គន់ស្អាតដោយប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកសហគមន៍

ការតបណ្តាញទឹកពីស្រះសហគមន៍ បានធ្វើឱ្យអ្នកភូមិមានភាពប្រសើរឡើងនូវសុខភាពគួរឱ្យកត់សម្គាល់ និងកុមារចូលរៀនបានទៀងទាត់។ មុនអនុវត្តគម្រោង ភាគច្រើននៃសមាជិកសហគមន៍មិនមានបង្គន់ប្រើប្រាស់ទេ។ ជាទម្លាប់ សហគមន៍តែងតែចូលទៅព្រៃក្រោយផ្ទះដើម្បីបន្ទោបង់។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ មាន៤០គ្រួសារក្នុងចំណោម៦៥គ្រួសារ មានបង្គន់អនាម័យប្រើប្រាស់ជាមួយនឹងការតបណ្តាញទឹក បើប្រៀបធៀបទៅនឹងស្ថានសហគមន៍មុនអនុវត្តគម្រោង (រូបទី១១)។ ប្រជាជនក្នុងសហគមន៍ ជាពិសេសកុមារនាពេលបច្ចុប្បន្ននេះមានអានាម័យខ្លួនប្រាណដោយ បានងូតទឹកច្រើនជាងមុន។ មិនត្រឹមតែប៉ុណ្ណឹងទេ សហគមន៍អាចមានបន្លែបរិភោគដែលជួយដល់សុខភាព ដោយសហគមន៍អាចដាំបន្លែបាននៅរដូវប្រាំងសម្រាប់ហូប និងសម្រាប់លក់។ ជាលទ្ធផល គេសង្កេតឃើញថា ចំនួនប្រជាជនដែលបានទៅពិនិត្យសុខភាព នៅមណ្ឌលសុខភាពសហគមន៍ដើម្បីព្យាបាលជម្ងឺដូចជា ជម្ងឺរាគរូស រលាកបំពង់ក ត្រូវបានកាត់បន្ថយប្រមាណ៧០ភាគរយ (Vong, 2014)។

កុមារភាគច្រើន មានភារកិច្ចទទួលខុសត្រូវក្នុងការដងទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងសត្វពាហនៈ។ កុមារមួយចំនួនមិនបានចូលរៀនទៀងទាត់ដោយសារតែបន្ទុកគ្រួសារនេះ។ ប៉ុន្តែនាពេលនេះគ្រូ

បង្រៀនបានរាយការណ៍ថា កុមារឥឡូវនេះបានចូលរៀនពេញម៉ោង និងមកទៀងទាត់ដោយសារពួកគេមិនបានចំណាយពេលច្រើនក្នុងការទៅដងទឹកសម្រាប់គ្រួសារពួកគេដូចមុនទៀតទេ គេសង្កេតឃើញថា ការពិតមានការកាត់បន្ថយ ការកាប់ឆ្ការព្រៃពីសមាជិកសហគមន៍ដោយសារសមាជិកសហគមន៍ បានផ្លាស់ប្តូរមុខរបរចិញ្ចឹមជីវិត។

លើសពីនេះទៅទៀត ស្ត្រីនៅក្នុងភូមិ បានលើកទឹកចិត្តឱ្យចូលរួមក្នុងការរៀបចំនិងអនុវត្តគម្រោង។ ចាប់ផ្តើមពីដំណាក់កាលរៀបចំគម្រោង ស្ត្រីត្រូវបានពិគ្រោះយោបល់ ពីភាពខ្វល់ខ្វាយ និងទស្សនៈរបស់ស្ត្រី ត្រូវបានទទួលយកនិងដាក់បញ្ចូលក្នុងរបាយការណ៍ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(VRA) ដែលជាព័ត៌មានគ្រឹះសម្រាប់ការរៀបចំគម្រោង។ ស្ត្រីត្រូវបានជម្រុញលើកទឹកចិត្តឱ្យចូលរួមក្នុងកិច្ចប្រជុំ ការចូលរួមសម្រេចចិត្ត និងបណ្តុះបណ្តាលនានា។ ជាឧទាហរណ៍ ក្រុមសន្សំប្រាក់ចំនួន៤ ដែលបានបង្កើតឡើងបានជម្រុញឱ្យស្ត្រីក្នុងគ្រួសារចុះឈ្មោះជាសមាជិកក្រុមសន្សំដើម្បីចូលរួមក្នុងការរកប្រាក់ចំណូលក្នុងគ្រួសារ ។ ជាមួយនឹងការចូលរួមគាំទ្រថវិកាពីគម្រោងចំនួន៥០០ដុល្លារអាមេរិកជាទុនសម្រាប់ក្រុមសន្សំនីមួយៗ ហើយស្ត្រីសមាជិកអាចដាក់ប្រាក់ជាកញ្ចប់រៀងៗខ្លួនបញ្ចូលគ្នាក្នុងប្រាក់សន្សំក្រុម ដើម្បីប្រមូលការប្រាក់នៅពេលក្រោយ។ ក្នុងករណីត្រូវការប្រាក់បន្ទាន់ ឬចាប់ផ្តើមមុខរបរអាជីវកម្មខ្នាតតូច ស្ត្រីអាចខ្ចីថវិកាពីក្រុមសន្សំជាមួយនឹងអត្រាការប្រាក់ទាប បើប្រៀបធៀបទៅនឹងសេវាកម្មមីក្រូហិរញ្ញវត្ថុឯកជន។

ចំនួនអ្នកភូមិដែលធ្លាប់ចូលទៅក្នុងព្រៃដើម្បីប្រមូលផលអនុផលព្រៃឈើត្រូវបានថយចុះ(រូបថតទី១៣)។ ការថយចុះនេះដោយសារតែពួកគាត់មិនបានចំណាយពេលច្រើនដូចមុនដើម្បីស្វែងរកទឹក ដូចពីមុន (៤ទៅ៥ម៉ោងក្នុងថ្ងៃ)។ ដូច្នេះ ពួកគាត់មានពេលវេលាសម្រាប់ស្វែងរកការងារផ្សេងៗធ្វើ ដូចជា កម្មករសំណង់ ដាំបន្លែគ្រួសារ ការចិញ្ចឹមសត្វ និងចិញ្ចឹមត្រីក្នុងស្រះដើម្បីរកចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ពួកគាត់។ លើសពីនេះទៅទៀត សមាជិកសហគមន៍បានកើនចំណេះដឹងប្រសើរ ជាងមុនអំពីទំនាក់ទំនងរវាងព្រៃឈើ និងប្រភពទឹកដែលបានជម្រុញពួកគាត់ងាកមករកការខិតខំប្រឹងប្រែងកិច្ចការពារព្រៃសហគមន៍(រូបថត១៣)។ ពួកគាត់បានបង្ហាញថា ការកាប់បំផ្លាញព្រៃឈើនាំឱ្យមានកង្វះខាតទឹក។ ការយល់ដឹងនេះ បានធ្វើឱ្យមានការកើនឡើងនៃការចូលរួមរបស់សហគមន៍ក្នុងការការពារ ព្រៃឈើពីការកាប់ឈើខុសច្បាប់។ ពួកគាត់យល់ថាការការពារព្រៃឈើសហគមន៍នឹងជួយស្រូបយកទឹកបានច្រើនដើម្បីស្តុកក្នុងអាងទឹក។ លើសពីនេះទៅទៀត ចំនួនសត្វព្រៃដូចជាជ្រូកព្រៃ និងឈ្លូសត្រូវបានកត់សម្គាល់ថាមានការកើនឡើងច្រើនផងដែរដោយសារសកម្មភាពអភិរក្សព្រៃឈើ និងមានទឹកគ្រប់គ្រាន់។ ការមានទឹកគ្រប់គ្រាន់ក៏បានជួយប្រជាជនក្នុងការថែរក្សាព្រៃឈើក្នុងករណីមានភ្លើងឆេះព្រៃកើតឡើង ពិសេសក្នុងអំឡុងពេលរដូវប្រាំង។ ជាលទ្ធផល ពួកគាត់បានយល់កាន់តែប្រសើរឡើងអំពីការគ្រប់គ្រងទីជម្រាលដែលបានធ្វើឱ្យប្រសើរឡើងនូវជីវភាព និងធនធានធម្មជាតិ។



រូបភាព១៣: ការថែទាំព្រៃឈើ បង្កើនធនធានធម្មជាតិ និងបរិមាណទឹកក្នុងអាងស្តុកទឹក

## ៣.៥ ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកសហគមន៍

ការបង្កើតគណៈកម្មការគ្រប់គ្រងទឹក គឺជាយន្តការគោលការណ៍ដើម្បីធានានិរន្តរភាពគម្រោង។ គណៈកម្មការបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាការគ្រប់គ្រងឱ្យបានល្អ នូវការថែទាំប្រព័ន្ធទុយោទឹក និងអាងស្តុកទឹករួមទាំងកុងទ័រអំឡុងពេល និងបន្ទាប់ពីគម្រោងបានបញ្ចប់។ ការពង្រឹងសមត្ថភាពលើការគ្រប់គ្រងទឹកបានផ្តល់ជូនដល់គណៈកម្មការគ្រប់គ្រងទឹកដើម្បីឱ្យពួកគាត់អាចគ្រប់គ្រងប្រព័ន្ធទឹក និងប្រើប្រាស់បានយូរអង្វែង។ ជាឧទាហរណ៍ គណៈកម្មការគ្រប់គ្រងទឹកមានលទ្ធភាពពង្រីកបណ្តាញទុយោទៅភូមិផ្សេងៗ ដោយប្រើប្រាស់ថវិកាដែលបានមកពីការប្រមូលសេវាបង់ថ្លៃទឹក និងការខ្ចីប្រាក់ពីបណ្តាញរបស់ពួកគាត់។ ថ្លៃទឹកគឺបានប្រមូលពីអ្នកប្រើប្រាស់ទឹក ហើយត្រូវបានគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងទឹកនឹងអាចយកទៅប្រើប្រាស់សម្រាប់ប្រយោជន៍ផ្សេងៗរបស់សហគមន៍។ នៅឆ្នាំ២០១៣ ការចំណាយថវិកាបម្រុងសម្រាប់ការថែទាំ និងជួសជុល (O&M) ប្រព័ន្ធផ្គត់ផ្គង់ទឹកអស់ប្រហែលជា១០០ដុល្លារ។ ថវិកាដែលនៅសល់ពី O&M ត្រូវបានប្រើប្រាស់ដើម្បីបំពេញបន្ថែមទៅក្នុងក្រុមសន្សំប្រាក់នៅក្នុងឆ្នាំ២០១២។ ថវិកាមួយផ្នែកនៃសេវាថ្លៃទឹកដែលពួកគាត់ប្រមូលបានជារៀងរាល់ខែបានវិភាជន៍ទៅលើការគាំទ្រដល់ អ្នកស្ម័គ្រចិត្តដើម្បីអនុវត្តន៍ការងារល្បាតព្រៃ ទប់ស្កាត់បទល្មើសព្រៃឈើ និងភ្លើងឆេះព្រៃ។

# ៤. បញ្ហាប្រឈមនានា

បើទោះបីជាគម្រោងបន្សាំនេះ បានផ្តល់នូវលទ្ធផលជាផ្លែផ្កា តែនៅមានបញ្ហាប្រឈមមួយចំនួនបានកើតឡើងដោយសារគម្រោងមានរយៈពេលខ្លី។ ការគាំទ្របន្ថែម និងពេលវេលាគួរត្រូវបានផ្តល់ជូនដល់គណៈកម្មការគ្រប់គ្រងទឹកដើម្បីទទួលបានការគាំទ្របច្ចេកទេសលើការគ្រប់គ្រងសហគមន៍ផ្គត់ផ្គង់ទឹក និងការអនុវត្តតួនាទីរបស់ខ្លួនដើម្បីឱ្យពួកគាត់ធ្វើការប្រកបដោយជំនាញវិជ្ជាជីវៈ។ ការកសាងអាងស្តុកទឹកបានផ្តល់ការផ្គត់ផ្គង់ទឹកតាមរយៈបណ្តាញទុយោទឹកទៅសហគមន៍ព្រៃឈើក្រាំងសេរីដែលអាចជួយដល់ការកែលម្អជីវភាពរបស់ពួកគាត់។ ក្នុងករណីសមាជិកសហគមន៍ជាច្រើនបានប្រើប្រាស់ទឹកក្រៅពីការប្រើប្រាស់ក្នុងគ្រួសារដូចជាការស្រោចស្រព និងការចិញ្ចឹមសត្វគណៈកម្មការគ្រប់គ្រងទឹកនឹងទទួលរងបញ្ហាប្រឈមថ្មីមួយចំនួនរួមមានការគ្រប់គ្រងទឹក និងការបំពុលទឹកពីសកម្មភាពទាំងនេះ។ បញ្ហាប្រឈមផ្សេងទៀតក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកគឺសមាជិកសហគមន៍មួយចំនួន មិនបានអនុវត្តន៍តាមបទបញ្ជា/លក្ខន្តិកៈនៃការប្រើប្រាស់ទឹក ហើយអ្នកភូមិបានប្រើប្រាស់ទឹកច្រើនលើសលុបសម្រាប់ស្រោចស្រពដំណាំ និងបង្ហូរចូលស្រែ។ លើសពីនេះ ស្របពេលដែលក្រុមទទួលផលបានកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ (ត្រឹមតែ៦៧គ្រួសារនៅក្នុងឆ្នាំ២០១២, កើនឡើងចំនួន២០គ្រួសារថែមទៀតនៅក្នុងឆ្នាំ២០១៣ និងកើន៣៥គ្រួសារថែមទៀតនៅក្នុងដើមឆ្នាំ២០១៥), សមត្ថភាពគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក និងការប្រមូលចំណូលរបស់គណៈកម្មការបាន និងកំពុងប្រឈមមុខផងដែរ។

ទោះបីជាសមាជិកសហគមន៍អាចប្រើប្រាស់ទឹកតាមរយៈការផ្គត់ផ្គង់តាមទុយោទឹកក៏ដោយ ក៏គុណភាពទឹកនៅក្នុងអាងទឹកអាចនឹងមានបញ្ហាដល់សុខភាពទៅថ្ងៃអនាគត ដោយសារតែសមាជិក សហគមន៍មួយចំនួនបានចាប់ផ្តើមដាំដំណាំនៅផ្នែកខាងលើនៃអាងទឹក ហើយអ្នកដាំដំណាំទាំងនោះអាចនឹងប្រើជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិត។ ដូចនេះ គុណភាពអន់នៃទឹកក្នុងអាង អាចនាំនូវមេរោគមួយចំនួនតាមប្រព័ន្ធទុយោទឹក ប្រសិនបើមិនមានការធ្វើប្រព្រឹត្តិកម្មទឹកទេនោះ។ លើសពីនេះទៅទៀត ទាក់ទងទៅនឹង ការប្រមូលសេវាថ្លៃទឹក (៥០០ រៀល ឬ ០.១២៥ ដុល្លារ/ម៉ែត្រគូប) របស់គណៈកម្មការសហគមន៍ផ្គត់ផ្គង់ទឹក ថវិកានេះនៅមានចំនួនតិចតួចសម្រាប់សហគមន៍ប្រើប្រាស់ដើម្បីថែទាំបណ្តាញទុយោ និងអាងស្តុកទឹកក្នុងករណីមានការខូចខាតធ្ងន់ធ្ងរ។ ប្រសិនបើគណៈកម្មការគ្រប់គ្រងទឹកចង់ពង្រីកបណ្តាញទុយោទៅភូមិផ្សេងនៅក្បែរគ្នា គណៈកម្មការនេះត្រូវមានផែនការគ្រប់គ្រងថវិកាសម្រាប់ការពង្រីកបណ្តាញទុយោទឹកនេះទៅភូមិជិតខាង។ បញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះគឺ គណៈកម្មការគ្រប់គ្រងទឹកបានទទួលបានប្រាក់ឧបត្ថម្ភតិចតួចបំផុត (៥០០០រៀល=១.២៥ដុល្លារ/ខែ) ដូច្នេះ វាជាការលំបាកណាស់ក្នុងការស្វែងរកអ្នកស្ម័គ្រចិត្ត និងទីប្រឹក្សាដែលមានឆន្ទៈក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកសម្រាប់សហគមន៍ឱ្យបានយូរអង្វែង។

# ៥.ការអនុវត្តល្អៗ និងមេរៀនសម្រាប់ការរៀនសូត្រ

លទ្ធផលសម្រេចបានបន្ទាប់ពីគម្រោងបានបញ្ចប់បានផ្តល់ដល់យើងនូវការទទួលបានការអនុវត្តល្អៗ និងមេរៀនសម្រាប់ការរៀនសូត្រ បើទោះបីជាគម្រោងបានអនុវត្តន៍តែក្នុងរយៈពេលមួយឆ្នាំក៏ដោយ។

**ការអនុវត្តល្អ**

- ពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូផ្សេងៗទៀតដែលបានគាំទ្រគម្រោងនេះប្រកបដោយជោគជ័យ។ ជាក់ស្តែង អង្គការម្លប់បៃតងបានសម្របសម្រួលដំណើរការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ(VRA) និងបានជួយរៀបចំគម្រោងសំណើព្រមទាំងការសរសេររបាយការណ៍ អំឡុងពេលអនុវត្តគម្រោង។ អង្គការទស្សនៈពិភពលោកកម្ពុជាក៏បានចូលរួមដល់ការតម្លើងបណ្តាញទុយោទឹក។ ក្រុមប្រឹក្សាឃុំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តន៍គម្រោង និងធ្វើការជិតស្និទ្ធជាមួយគណៈកម្មការសហគមន៍ព្រៃឈើដើម្បីប្រមូលមូលនិធិពីអ្នកភូមិនីមួយៗដើម្បីតភ្ជាប់ពីទុយោមេទៅតាមគ្រួសាររបស់ពួកគាត់។
- ការជ្រើសរើសទីតាំងគម្រោងសម្រាប់កសាងអាងស្តុកទឹក និងតម្លើងប្រព័ន្ធទុយោទឹក បានធ្វើឱ្យអ្នកទទួលផលបានទឹកប្រើប្រាស់ដោយបង្ហូរតាមលក្ខណៈធម្មជាតិ ដោយមិនចាំបាច់ធ្វើការបូមទេ។
- កិច្ចប្រជុំជាមួយអ្នកទទួលផលពីគម្រោងបានទៀងទាត់ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងទឹក និងការគ្រប់គ្រងថវិកាដើម្បីជៀសវាងជម្លោះ និងការប៉ះទង្គិចផលប្រយោជន៍ផ្ទៃក្នុង
- ការលើកកម្ពស់ឱ្យមានភាពជាម្ចាស់និងការកសាងសមត្ថភាពកាន់តែច្រើនបានផ្តល់ឱ្យប្រសើរឡើងនូវការធ្វើការសម្រេចចិត្តក្នុងការអនុវត្តគម្រោងនេះ។
- មានការគាំទ្រយ៉ាងខ្លាំងពីអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការអនុវត្តន៍គម្រោងនិងការធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការការគ្រប់គ្រងទឹកដើម្បីប្រមូលថវិកាបដិភាគពីអ្នកភូមិក្នុងការតភ្ជាប់ទុយោទឹកចូលតាមផ្ទះពីទុយោមេ។ មិនត្រឹមតែមានការគាំទ្រពីបណ្តាអង្គការ និងអាជ្ញាធរប៉ុណ្ណោះទេ តែក៏មានការគាំទ្រយ៉ាងខ្លាំងពីព្រឹទ្ធាចារ្យនៅក្នុងភូមិធ្វើឱ្យអ្នកទទួលផលមានសាមគ្គីភាពដ៏រឹងមាំ
- ការផ្តល់ជំនាញបច្ចេកទេសដល់ប្រធានសហគមន៍ដើម្បីក្លាយជាអ្នកជំនាញខាងបច្ចេកទេសតភ្ជាប់បណ្តាញទុយោទឹក និងការគ្រប់គ្រងទឹក។ ជាឧទាហរណ៍ អ្នកជំនាញតទឹកនេះបានជួយត និងដំឡើងបណ្តាញទឹកតាមផ្ទះបាន៣គម្រោងដល់អង្គការទស្សនៈពិភពលោកចំនួនមួយគម្រោង និងរបស់អង្គការដំណក់ទឹកភ្លៀងកម្ពុជា (RWC) ចំនួន ២ គម្រោង។

**មេរៀនសម្រាប់ការរៀនសូត្រ**

- ការរៀបចំតបណ្តាញទុយោទឹកដោយមានលក្ខណៈហូរសេរីពីអាងស្តុកទឹកទៅតាមផ្ទះ បានប្រែក្លាយសហគមន៍ដែលធ្លាប់តែខ្វះខាតទឹកជាប្រចាំ ឱ្យទៅជាសហគមន៍មួយដែលមានអតិរេកទឹក (ទឹកលើសតម្រូវការ) សម្រាប់ទាំងការប្រើប្រាស់ក្នុងផ្ទះ និងជម្រើសនានាសម្រាប់ជីវភាពរស់នៅដូចជាការធ្វើសួនបន្លែគ្រួសារ និងចិញ្ចឹមសត្វ។
- បញ្ហាប្រឈមពិតប្រាកដរបស់សហគមន៍(ការខ្វះខាតទឹកសម្រាប់ប្រើប្រាស់ទឹកតាមផ្ទះ (ជាហេតុធ្វើអោយទាក់ទាញម្ចាស់ជំនួយដើម្បីគាំទ្រ និងលើកទឹកចិត្តសហគមន៍ជាម្ចាស់លទ្ធផលគម្រោង។
- ការគ្រប់គ្រងល្អនៃគណៈកម្មការទឹកនាំឱ្យមានការកើនឡើងអ្នកទទួលផលគម្រោងពី៦៧ គ្រួសារទៅ ១២២គ្រួសារ ហើយចម្លងបទពិសោធទៅតំបន់គម្រោងផ្សេងទៀត។
- ការផ្តល់ទឹកដល់ផ្ទះសម្រាប់ក្រុមគ្រួសារតាមរយៈតបណ្តាញប្រព័ន្ធទុយោ និងការមានទឹកគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ពេញឆ្នាំធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមានលើការងារអនាម័យគ្រួសារ ដោយមានការសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកតាមគ្រួសារ ដោយស្ម័យប្រវត្តិ។
- កិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន បានធ្វើឱ្យលទ្ធផលគម្រោងមាននិរន្តរភាព។

វាជាឱកាសល្អដល់សហគមន៍ដែលចាប់អារម្មណ៍ និងម្ចាស់ជំនួយផ្សេងៗទៀតដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ដូចជាការកសាងបង្គន់ដោយសមាជិកសហគមន៍ដោយមិនមានការគាំទ្រមូលនិធិពីខាងក្រៅនិងការផ្តល់បច្ចេកទេសកសិកម្មបន្ទាប់ពីសហគមន៍មានទឹកប្រើប្រាស់សម្រាប់ការស្រោចស្រព។ គម្រោងនេះបានឆ្លុះបញ្ចាំងអំពីគំរូល្អមួយសម្រាប់ការគ្រប់គ្រងទឹកដើម្បីបន្ស៊ាំទៅនឹងគ្រោះរាំងស្ងួត នៅតំបន់ភ្នំ និងផ្តល់ជាឧទាហរណ៍ល្អមួយដើម្បីពង្រីកការអនុវត្តដល់គម្រោងផ្សេងៗនៅក្រោមការគាំទ្រអង្គការទស្សនៈពិភពលោកកម្ពុជា និងអង្គការតំណក់ទឹកភ្លៀងកម្ពុជា( RWC)។ លើសពីនេះ សហគមន៍ព្រៃឈើក្រាំងសេរី ក៏មានឱកាសក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រងអាជីវកម្មខ្នាតតូចក្នុងសហគមន៍ដែលផ្អែកលើការផ្គត់ផ្គង់ទឹក។

ចាប់តាំងពីគម្រោងបានបញ្ចប់ អាជ្ញាធរឃុំមានសេចក្តីសប្បាយរីករាយដែលបានឃើញជីវភាពរស់នៅរបស់ប្រជាជនមានភាពរីកចំរើន ហើយគាត់មានឆន្ទៈនឹងបន្តគាំទ្រសហគមន៍ឱ្យបានយូរអង្វែង។ ប្រធានក្រុមប្រឹក្សាឃុំ និងតាងនាមឱ្យអាជ្ញាធរមូលដ្ឋានបានស្នើសុំយ៉ាងទទូចដល់ម្ចាស់ជំនួយគម្រោងដើម្បីពិចារណាពង្រីកការអនុវត្តន៍គម្រោងដែលមានភាពស្រដៀងគ្នានេះទៅភូមិជិតៗសហគមន៍ព្រៃឈើនោះ ដែលកំពុងទទួលរងគ្រោះពីកង្វះខាតទឹក និងជីវភាពលំបាក។ ដូច្នេះសមិទ្ធិផល និងផលប្រយោជន៍សេដ្ឋកិច្ចសង្គមពីគម្រោងបានធ្វើឱ្យអាជ្ញាធរឃុំដាក់បញ្ចូលការបន្ស៊ាំការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីអភិវឌ្ឍន៍ឃុំ។

# ៦. សន្និដ្ឋាន និងអនុសាសន៍

គម្រោងនេះទទួលបានផលជាវិជ្ជមាន ដោយបានសម្រេចគោលដៅទូទៅរបស់គម្រោង និងដើម្បីធានាឱ្យបាននូវនិរន្តរភាព។ លទ្ធផលនៃគម្រោងនេះបានឆ្លើយតបយ៉ាងល្អ ទៅនឹងតម្រូវការរបស់សហគមន៍ និងអ្នកទទួលផលរបស់គម្រោង។ សហគមន៍ក្រាំងសេរីសម្រេចបានទាំងសមត្ថភាពដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ទឹករបស់សហគមន៍ និងពង្រឹងសាមគ្គីភាពដើម្បីរក្សាបានប្រព័ន្ធនេះ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។ គម្រោងនេះអាចត្រូវបានចាត់ទុកជាគំរូដ៏ល្អមួយសម្រាប់សហគមន៍ផ្សេងទៀតដែលមានលក្ខខណ្ឌភូមិសាស្ត្រស្រដៀងគ្នាដើម្បីអនុវត្តតាម។ សន្តិសុខទឹកត្រូវបានគេកំណត់ថាជាបញ្ហាប្រឈមដ៏សំខាន់នៅក្នុងសហគមន៍ ដូច្នេះហើយវាត្រូវបានផ្តល់អាទិភាពជាដំណោះស្រាយរយៈពេលវែងឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ នៅក្នុងចំណោមសហគមន៍ក្រាំងសេរី។ ការសាងសង់អាងស្តុកទឹក និងការដំឡើងនៃប្រព័ន្ធទុយោទឹកបានធ្វើឱ្យគ្រោះរាំងស្ងួត និងការខ្វះទឹកលែងជាឧបសគ្គដ៏សំខាន់សម្រាប់សមាជិកសហគមន៍ទាំងមូល។ ការគ្រប់គ្រងទឹកបានមកពីតំបន់ភ្នំ អាចជួយសហគមន៍ក្នុងការសម្របខ្លួនទៅនឹងការធ្លាក់ភ្លៀងមិនទៀងទាត់ដែលមានការប្រែប្រួលរបបទឹកភ្លៀង ការអូសបន្លាយនៃគ្រោះរាំងស្ងួតរាល់ឆ្នាំឬក្នុងរដូវវស្សា ជាមួយនឹងការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារពេញមួយឆ្នាំ។ គម្រោងនេះបានប្រែក្លាយសហគមន៍ដែលកង្វះទឹកទៅជាសហគមន៍ដែលមានអតិរេកទឹកដែលអាចផ្គត់ផ្គង់ឱ្យទៅភូមិផ្សេងទៀតនៅក្បែរនោះ។ លើសពីនេះទៅទៀតការបណ្តុះបណ្តាលជាច្រើនរួមបញ្ចូលទាំងការគ្រប់គ្រងនៃប្រព័ន្ធផ្គត់ផ្គង់ទឹកមូលដ្ឋានការគ្រប់គ្រងហិរញ្ញវត្ថុ ការសរសេររបាយការណ៍ ការដាំបន្លែគ្រួសារ និងការចិញ្ចឹមសត្វត្រូវបានផ្តល់ទៅឱ្យសមាជិកគណៈកម្មការ និងសហគមន៍ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេសម្រាប់ជម្រើសការគាំទ្រជីវភាពរស់នៅ។ ពួកគេមិនចាំបាច់ចំណាយពេលវេលាទៅលើការស្វែងរកទឹក ដូច្នេះពួកគេអាចចំណេញពេលវេលាសម្រាប់ជម្រើសការងារផ្សេងៗដើម្បីគាំទ្រជីវភាពរស់នៅ។ ជាលទ្ធផលជីវភាពរស់នៅរបស់សហគមន៍នេះ បានប្រសើរឡើង ហើយពួកគេបានបង្កើនសមត្ថភាពបន្សាំរបស់ពួកគេដើម្បីដោះស្រាយគ្រោះរាំងស្ងួតដែលអូសបន្លាយដែលជាលទ្ធផលពីការប្រែប្រួលអាកាសធាតុ។

តាំងពីចាប់ផ្តើមរៀបចំគម្រោងដំបូងមកម្ល៉េះ សមាជិកសហគមន៍បានកំណត់សកម្មភាពរបស់គម្រោងនេះជាអាទិភាពចំបងរបស់ខ្លួន។ សហគមន៍នេះ បានរៀបចំគម្រោងដោយដាក់បញ្ចូលតម្រូវការជាអាទិភាពរបស់ពួកគាត់ចូលទៅក្នុងសកម្មភាពអនុវត្តគម្រោង។ គម្រោងនេះបានលើកកម្ពស់ភាពជាម្ចាស់ និងការចូលរួមយ៉ាងសកម្មចាប់តាំងពីការពិគ្រោះយោបល់តាមរយៈការប្រើប្រាស់ឧបករណ៍VRA។ ដំណើរការវាយតម្លៃពីការកាត់បន្ថយភាពងាយរងគ្រោះ(VRA) នេះបាននាំឱ្យអ្នកភូមិទាំងអស់បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនេះជាអ្វីដែលពួកគេត្រូវការជាចាំបាច់ហើយអ្វីដែលពួកគេនឹងធ្វើនៅពេលក្រោយ។ សហគមន៍បានសម្រេចចិត្តដោយខ្លួនឯងផ្ទាល់ក្នុងការកំណត់ថ្លៃទឹកឱ្យបានសមរម្យពីគ្រួសារនីមួយៗដើម្បីគាំទ្រដល់ការថែរក្សានៃអាងស្តុកទឹកនិងប្រព័ន្ធទុយោទឹក។ គំនិតផ្តួចផ្តើមនេះ ត្រូវបានទទួលស្គាល់គាំទ្រ និងចូលរួមដោយអ្នកភូមិ និងអាជ្ញាធរឃុំ។ សហគមន៍ក្រាំងសេរីបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំក្នុងការគ្រប់គ្រងអង្គភាពនៃក្រុមសន្សំ និងដើម្បីជួយដោះស្រាយជម្លោះ ដែលទាក់ទងទៅនឹងការងារហិរញ្ញវត្ថុ ណាមួយរបស់ក្រុមសន្សំ និងសេវាបង់ថ្លៃទឹកក្នុងសហគមន៍ ។ ការងារនេះបានបង្ហាញថាពួកគេបានចូលរួមក្នុងការដោះស្រាយបញ្ហាសហគមន៍ និងបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងផលប្រយោជន៍រួម។ ដូច្នេះ អាជ្ញាធរឃុំបានពិចារណាដាក់ប្រភេទគម្រោងមួយនេះចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

អនុសាសន៍មួយចំនួនសម្រាប់ធ្វើឱ្យប្រសើរឡើងនាពេលអនាគតនៃគម្រោងស្រដៀងគ្នាឬការបន្តគម្រោងដែលមានស្រាប់ដូចខាងក្រោមៈ

- ផលិតផែនទីនៃបណ្តាញទឹកទុយោមួយដើម្បីងាយស្រួលដល់ការងារថែទាំ។
- ការរៀបចំផែនការគ្រប់គ្រងថវិកាសម្រាប់ការប្រើប្រាស់ការប្រមូលថ្លៃឈ្នួលទឹកប្រកបដោយប្រសិទ្ធិភាព។
- ត្រួតពិនិត្យសមត្ថភាពអាងស្តុកទឹក និងចាត់វិធានការជាបន្ទាន់ដើម្បីគ្រប់គ្រងការប្រើប្រាស់ទឹកនៅពេលដែលសមត្ថភាពផ្គត់ផ្គង់ទឹកធ្លាក់ចុះដល់កម្រិតមួយដែលការផ្គត់ផ្គង់សម្រាប់តែតម្រូវការប្រើប្រាស់តាមផ្ទះត្រូវបានអនុញ្ញាត។
- ការកែលម្អបទប្បញ្ញត្តិការប្រើប្រាស់ទឹកសម្រាប់គោលបំណងផ្សេងទៀតដូចជាការស្រោចស្រព និងការចិញ្ចឹមសត្វក្នុងគោលបំណងដើម្បីកាត់បន្ថយជម្លោះនៃការបែងចែកផលប្រយោជន៍ក្នុងចំណោមសមាជិកសហគមន៍
- ជំរុញការគ្រប់គ្រងទីជម្រាលដើម្បីរក្សាការស្តុកទឹកនិងគុណភាពទឹកតាមរយៈការកែលម្អតម្របព្រៃឈើ និងការកាត់បន្ថយការបំពុលដែលអាចហូរទៅដល់រូបីណេរបស់គ្រួសារនីមួយៗ។ ការបំពុលទំនងមកពីជីគីមី និងថ្នាំសម្លាប់សត្វល្អិតដែលគេប្រើនៅលើកសិដ្ឋាននៅជុំវិញ និងភាគខាងលើនៃអាងស្តុកទឹកនេះ។ នេះជាការផ្តល់អនុសាសន៍យ៉ាងខ្លាំងសម្រាប់ សហគមន៍ក្រាំងសេរីដើម្បីបង្កើតយន្តការត្រួតពិនិត្យការបំពុលដែលអាចកើតឡើងបាន។
- បង្កើនការពង្រីកគម្រោងទៅសហគមន៍ដទៃទៀតនៅក្បែរនោះដែលជាកន្លែងដែលមានទីតាំងសក្តានុពលសម្រាប់ការសាងសង់អាងស្តុកទឹកនិងការបែងចែកការផ្គត់ផ្គង់ទឹកដែលទាញចេញពីអាងស្តុកទឹក។

# ៧. ឯកសារយោង


1 NGO Forum. 2012. "Impact of climate change on rice production in Cambodia". NGO Forum on Cambodia: Phnom Penh.

2 NCDM report 2008.

3 VRA Report. 2011. Vulnerability Reduction Assessment in Kraing Serei Community Forestry, Kampong Speu, 25 p.

4 VONG M. 2014. Paper nominated for Equator Prize 2014. 6p.

5 Evaluation Report. 2012. Water Supply System Development and Livelihood Improvement- (WSSDLI) for Krang Serei Community Forestry Members, 24 p.

# ករណីសិក្សា២

## បង្កើនសមត្ថភាពសហគមន៍ដើម្បីបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ
## នៅក្នុងឃុំស៊ាង ឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង



# មាតិកា


| | |
|---|---|
| **១. សាវតា និងគោលបំណង** | 26 |
| **២. វិធីសាស្រ្ត និងអភិក្រមនៃគម្រោង** | 28 |
| ២.១ ការកំណត់តម្រូវការអាទិភាពរបស់សហគមន៍ | 28 |
| ២.២ ជម្រុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការ | 28 |
| ២.៣ ការស្តារប្រឡាយស្រោចស្រព និងលើកផ្លូវថ្មី | 29 |
| ២.៤ បង្កើតគណៈកម្មការប្រើប្រាស់ទឹក( FWUC ) និងធនាគារស្រូវ | 30 |
| ២.៥ ការបង្កើតក្រុមសន្សំប្រាក់ | 31 |
| ២.៦ ការពង្រឹងសមត្ថភាព និងការផ្តល់សិទ្ធអំណាចដល់សហគមន៍ | 32 |
| **៣. សមិទ្ធិផលបណ្តោះអាសន្ន និងលទ្ធផល** | 33 |
| ៣.១ ការធ្វើឱ្យប្រសើរឡើងនៃការដាំដុះដំណាំស្រូវតាមរយៈការស្តារប្រឡាយ | 3 |
| ៣.២ ការពង្រឹងសមត្ថភាពលើទស្សនៈទានការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនាគារស្រូវ ប្រឡាយនិងបច្ចេកទេសកសិកម្ម | 4 |
| ៣.៣ ភាពជោគជ័យលើការគ្រប់គ្រងធនាគារស្រូវ ការថែទាំង និង ប្រើប្រាស់ប្រឡាយ | 5 |
| ៣.៤ ជីវភាពបានកែលម្អប្រសើរឡើងបន្ទាប់ពីការអនុវត្តគម្រោង | 36 |
| ៣.៥ ការធ្វើអោយប្រសើរឡើងនូវវិធីសាស្រ្តដែលមានការចូលរួមចំរុះដើម្បីឱ្យមាននិរន្តរភាពរបស់គម្រោង | 38 |
| **៤. បញ្ហាប្រឈមសំខាន់ៗ** | 40 |
| **៥. ការអនុវត្តល្អៗ និងមេរៀនសម្រាប់ការរៀនសូត្រ** | 41 |
| **៦. សន្និដ្ឋាន និងអនុសាសន៍** | 42 |
| **៧. ឯកសារយោង** | 43 |

# ១. សារតា និងគោលបំណង

ខេត្តព្រៃវែងមានចំងាយប្រមាណជា៩០គ.ម ពីទីក្រុងភ្នំពេញដែលស្ថិតនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា មានក្រឡាផ្ទៃដីចំនួន៤.៨៨៣ គីឡូម៉ែត្រការ៉េ ដែលមាន ៦៣% ជាផ្ទៃដីកសិកម្ម និង ៤% ជាផ្ទៃដីព្រៃឈើ[1]។ ការកើនឡើងនៃកម្រិតទឹកជំនន់ និងគ្រោះរាំងស្ងួត ការថយចុះនៃទិន្នផលដំណាំ កង្វះខាតទឹក ការកើតជំងឺដោយសារទឹកកខ្វក់បានបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ខេត្តព្រៃវែងដែលជាខេត្តមួយត្រូវបានកំណត់ជាខេត្តដែលងាយរងគ្រោះបំផុតពីទឹកជំនន់ និងរងគ្រោះកម្រិតទី២ ពីគ្រោះរាំងស្ងួត[2]។ ខេត្តព្រៃវែងគឺជាខេត្តមួយក្នុងចំណោមខេត្តដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុក្នុងចំណោមខេត្តចំនួន១៧ផ្សេងទៀត នៅក្នុងប្រទេសកម្ពុជាដែលបានបញ្ជាក់នៅក្នុងផែនទីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុសម្រាប់តំបន់អាស៊ីអាគ្នេយ៍[3]។ "សីតុណ្ហភាពជាមធ្យមសម្រាប់រយៈពេល ២៥ឆ្នាំ ពី១៩៨៧ ទៅ ២០១១ គឺ២៨.២ អង្សាសេ សីតុណ្ហភាពមធ្យមអតិបរិមា ៣៣អង្សាសេ និងមធ្យមអប្បរមា២៣,៣អង្សាសេ។ របបទឹកភ្លៀងមធ្យមរយៈពេល ២៧ឆ្នាំពីឆ្នាំ១៩៨៥ ទៅឆ្នាំ២០១១ ប្រែប្រួលពី ៩៤៩មម ទៅ ១៨៦៧មម ដោយផ្អែកលើកម្រិតខ្ពស់បំផុតនៃឆ្នាំ១៩៩៦, ២០០០, ២០១០ និង២០១១ គឺ១៧០០មម" (NGOF, 2014)[4]។

ភូមិចំនួន១៣ នៃឃុំសាំងឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង ត្រូវបានជ្រើសរើសជាតំបន់គោលដៅគម្រោង។ ក្នុងតំបន់នេះ គេបានកំណត់អត្តសញ្ញាណនៃភាពក្រីក្រ (ID-Poor) ចំនួន ៣ប្រភេទ គឺក្រកម្រិត១ ក្រកម្រិត២ និងក្រតិចតួច។ ភូមិគោលដៅទាំងនោះរួមមានភូមិល្វា សង្កែ ឧបមា លាក់នឹម ត្នោត បុស្ស ឬស្សីជុំកទី១ ឬស្សីជុំកទី២ ចុងបឹង ទួលសុភី បាយ៉ាប គ្រួស និងភូមិឈូក។ ភូមិទាំងនេះមាន ២.៧៥៧គ្រួសារ ដោយមានប្រជាជនសរុប១០.៦៣៥នាក់ (ស្រី ៥៤៨៣នាក់)[5]។ ប្រជាជនប្រមាណ៩៧%ប្រកបមុខរបរធ្វើស្រែ និង ៣%ទៀតជាសហគ្រាសខ្នាតតូច និងឈ្មួញកណ្តាល[6]។ លើសពីនេះពួកគាត់ដាំបន្លែ ចិញ្ចឹមសត្វ លក់កម្លាំងពលកម្មក្នុងតំបន់ (ស៊ីឈ្នួលបាញ់ថ្នាំកសិកម្ម និងដាំដុះ) និងចំណាកស្រុកទៅខេត្ត/ក្រុងផ្សេងៗ (កម្មកររោងចក្រ) ហើយមួយចំនួនទៀត ជាពិសេសយុវជនបានធ្វើចំណាកស្រុកទៅប្រទេសជិតខាងដូចជា ថៃ ឬម៉ាឡេស៊ីជាដើម។

ផ្អែកលើលទ្ធផលនៃការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) ដែលបានធ្វើនៅថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១១ បង្ហាញថាភាគច្រើនបំផុតនៃប្រជាជនក្នុងតំបន់គោលដៅបានប្រឈមមុខជាមួយផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុកាលពី៥ឆ្នាំកន្លងទៅរួមមាន គ្រោះរាំងស្ងួតរយៈពេលវែង ការពន្យាពេលធ្លាក់ភ្លៀងដែលពុំអាចព្យាករណ៍បាននៅក្នុងរដូវវស្សាដែលធ្វើអោយប៉ះពាល់ដល់កង្វះខាតទឹកសម្រាប់ស្រោចស្រព និងការចិញ្ចឹមសត្វ។ ដោយសារតែបញ្ហាប្រឈមនឹងគ្រោះរាំងស្ងួតញឹកញាប់ អ្នកភូមិបានសម្រេចចិត្តជីកអណ្តូងស្នប់ដើម្បីយកទឹកក្រោមដីសម្រាប់ធ្វើកសិកម្ម។ តែទោះបីយ៉ាងណាក៏ដោយទឹកដែលបានពីការជីកអណ្តូងស្នប់នេះមិនគ្រប់គ្រាន់សម្រាប់ការធ្វើស្រែនោះទេ ហើយវាត្រូវការចំណាយខ្ពស់សម្រាប់ការប្រើប្រាស់ម៉ាស៊ីនបូមទឹក។ ការជីកអណ្តូងដើម្បីយកទឹកស្រោចស្រពស្រែ អាចបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ការប្រើប្រាស់អណ្តូងទឹកក្នុងភូមិ។

1 http://en.wikipedia.org/wiki/Prey_Veng_Province retrieved on 20 November 2014.
2 CCCA Project Factsheet August 2012: Together addressing climate change initiative - Prey Veng (TACCI-PV).
3 Yusuf & Francisco, January 2009. Climate Change Vulnerability Mapping for Southeast Asia. Economy and Environment Program for Southeast Asia (EEPSEA): Singapore.
4 NGOF, 2014. Farm conservation and sustainable use of cereal diversity through participatory plant breeding and securing local seed systems in climate vulnerable provinces of Cambodia, by Mr. Kim Soben.
5 Seang Kveang commune population data in 2011.
6 Seang Kveang commune situation Data Book 2011.

ប្រឡាយចាស់មួយឈ្មោះថា "ប្រឡាយរងក្បាលគោ ឬ ប្រឡាយត្រាលុងត្រុំ" មិនអាចប្រើប្រាស់បានទេ ដោយសារវាមិនអាចស្តុកទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែក្នុងរដូវវស្សា(រូបភាព១)។ ពួកគាត់បានធ្វើស្រែតែមួយដងក្នុងមួយឆ្នាំដោយពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង និងពេលខ្លះប្រឈមនឹងកូនរដូវប្រាំងក្នុងរដូវវស្សា ដែលបានកើតឡើងនៅចុងខែកក្កដា ដល់ពាក់កណ្តាលខែសីហា។ ជាលទ្ធផល បញ្ហានេះបណ្តាលឱ្យទិន្នផលស្រូវធ្លាក់ចុះ។ ប្រជាជនក្នុងតំបន់នេះបានជួបការលំបាកក្នុងការធ្វើដំណើរទៅស្រែ និងដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារ។ លើសពីនេះទៅទៀត ការអនុវត្តន៍ការធ្វើស្រែតាមបែបប្រពៃណី ដោយប្រើបច្ចេកទេសមិនសមស្រប និងការប្រើប្រាស់ថ្នាំកសិកម្មលើសលុបសម្រាប់ការដាំដុះបានបណ្តាលឱ្យបាត់បង់គុណភាពដី និងការធ្លាក់ចុះនៃទិន្នផលស្រូវទាបជាង២,៣តោនក្នុង១ហិកតា។ កសិករប្រើប្រាស់ជីគីមី ប្រហែល ១០០-១៥០គក្រ/ហិកតា និងថ្នាំកសិកម្មសម្រាប់ស្រូវអាចធ្វើឱ្យប៉ះពាល់ដល់ការចំណាយប្រចាំថ្ងៃសម្រាប់ជីវភាពរស់នៅ ពិសេសគ្រួសារដែលងាយរងគ្រោះ និងស្ត្រីជាមេគ្រួសារក្រីក្រ ព្រមទាំងការថយចុះនៃបរិស្ថានទាំងលើផ្ទៃដី និងទាំងផ្នែកក្រោមដី[7]។ ទាំងអស់នេះធ្វើឱ្យមានការប្រឈមទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដែលអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខស្បៀង ព្រមទាំងសុខភាពក្នុងតំបន់ផងដែរ។

ដើម្បីឆ្លើយតបនឹងបញ្ហាខាងលើ អង្គការលើកកំពស់ធនធានសហគមន៍ដើម្បីការអភិវឌ្ឍន៍ (CRID) បានផ្តួចផ្តើមគម្រោងបន្សាំមួយដោយមានការគាំទ្រមូលនិធិពីប្រទេសស៊ុយអែតតាមរយៈកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍(CCBAP) ក្រោមការគ្រប់គ្រងដោយកម្មវិធីជំនួយខ្នាតតូចរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP/Small/Grant Programme)។ ថវិកាសរុបនៃគំរោងទី១មានចំនួន ៥២.៣៥៤,៥៥ដុល្លារអាមេរិក ដែលក្នុងនោះ៤២.៥២៨,៨៤ដុល្លារទទួលបានពី UNDP/SGP/CCBAP និង ៩.៨២៥,៧១ដុល្លារ ទៀតជាបដិភាគរបស់អង្គការCRID និងសហគមន៍ ហើយ UNDP/SGP/CCBAP បានផ្តល់ថវិកាសំរាប់គម្រោងទី២ ដែលមានទឹកប្រាក់ចំនួន ៤៦.១៤២,០០ដុល្លារ បន្ថែមទៀត។ រយៈពេលអនុវត្តគម្រោងទី១ចាប់ផ្តើមពីខែធ្នូ ឆ្នាំ២០១១ រហូតដល់ ខែវិច្ឆិកា ឆ្នាំ២០១២ និងគម្រោងទី២ ពីខែធ្នូ ឆ្នាំ២០១២ រហូតដល់ខែវិច្ឆិកា ឆ្នាំ២០១៣។

គោលដៅសំខាន់របស់គម្រោង គឺដើម្បីកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះរាំងស្ងួត និងបង្កើនសមត្ថភាពរបស់សហគមន៍ ពិសេសកសិករក្រីក្រ និងស្ត្រីជាមេគ្រួសារដើម្បីបន្សាំទៅនឹងការប្រែប្រួលនៃរបបទឹកភ្លៀងតាមរយៈ ការស្តារប្រឡាយ បង្កើតធនាគារស្រូវ ការពង្រឹងសមត្ថភាពលើចំណេះដឹង និងជំនាញផលិតកម្មកសិកម្ម។ គោលបំណងពីរសំខាន់នៃគម្រោងគឺ

- ❖ បង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធស្រោចស្រពទឹកក្នុងចំណោមប្រជាជនងាយរងគ្រោះចំនួន២.២៤៦នាក់ (ស្រី១.១៤១នាក់) ក្នុងភូមិចំនួន ៣ នៃឃុំសាំងឃ្វាង សម្រាប់ផលិតកម្មដំណាំពីប្រឡាយដែលបានស្តារឡើងវិញប្រវែង ២១០០ម៉ែត្រ។
- ❖ បង្កើនទិន្នផលស្រូវសម្រាប់ ២៦០គ្រួសារ (ដែលមានស្ត្រីចូលរួមយ៉ាងតិច១០០នាក់) ក្នុងភូមិទាំង១៣ នៃឃុំ សាំងឃ្វាងពី ២,៣តោន/ហត ទៅ៤តោន/ហិកតា តាមរយៈការប្រើប្រាស់ពូជថ្មី និងការអនុវត្តន៍ចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាល។



រូបភាព១: ស្ថានភាពប្រឡាយមុនពេលគម្រោងអនុវត្តន៍

7 CRID proposal on "Community's capacity improvement for adaptation to CC in Seang Kveang, Kamchay Mear district, Prey Veng province", December 2011.

# ២. វិធីសាស្ត្រ និងអភិក្រមនៃគម្រោង

## ២.១ ការកំណត់តម្រូវការអាទិភាពរបស់សហគមន៍

យោងលើលទ្ធផល VRA, បញ្ហារួមដែលបានប្រឈមចំពោះសហគមន៍ពីការប្រែប្រួលអាកាសធាតុគឺកង្វះខាតទឹកសម្រាប់ផលិតកម្មកសិកម្មដូចជាដំណាំស្រូវ និងការចិញ្ចឹមសត្វ ផ្លូវធ្វើដំណើរទៅស្រែនៅមានការលំបាក និងការអនុវត្តន៍ការងារកសិកម្មតាមបច្ចេកទេសប្រពៃណី។ ដើម្បីឆ្លើយតបបញ្ហាទាំងនេះ សហគមន៍តំបន់គោលដៅបានឯកភាពថា សកម្មភាពជាអាទិភាពរួមមាន ស្តារប្រឡាយ បង្កើតគណៈកម្មការគ្រប់គ្រងប្រឡាយ ពង្រឹងសមត្ថភាពលើការកែលម្អបច្ចេកទេសកសិកម្មពិសេស ប្រពលវប្បកម្មដំណាំស្រូវ(បវស) បង្កើតធនាគារស្រូវ និងក្រុមសន្សំដើម្បីជួយគ្នាទៅវិញទៅមក ក្នុងគោលបំណង កែលម្អជីវភាពរស់នៅក្នុងតំបន់គោលដៅរបស់សហគមន៍។

## ២.២ ជម្រុញការចូលរួមរបស់អ្នកពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការ

បង្កើនការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ពិសេសសមាជិកសហគមន៍ អាជ្ញាធរឃុំ មន្ទីរជំនាញពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ និងអង្គការ គឺជាគន្លឹះសំខាន់ដែលនាំឱ្យគម្រោងសម្រេចបានជោគជ័យ។ គម្រោងបានជម្រុញឱ្យអ្នកទទួលផលចូលរួមអនុវត្តគ្រប់ដំណាក់កាលរួមមាន ការរៀបចំគម្រោង ការធ្វើផែនការគម្រោង ការអនុវត្តន៍ ការតាមដាន និងវាយតម្លៃ។ កសិករទទួលផលគម្រោងរួមមាន បុរសនិងស្ត្រីជាមេគ្រួសារធ្វើការដោយមានការសហការគ្នាដើម្បីកំណត់បញ្ហាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងកំណត់តម្រូវការអាទិភាពដើម្បីធ្វើឱ្យជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើង និងការចូលរួមថវិកាផ្ទាល់ខ្លួនរបស់គាត់ ព្រមទាំងកំលាំងពលកម្មដើម្បីស្តារប្រឡាយ កសាងផ្លូវការថែទាំ ការដាំដុះកូនឈើលើខ្នងប្រឡាយ និងការចូលរួមពូជស្រូវសម្រាប់និរន្តរភាពធនាគារស្រូវ។ អាជ្ញាធរមូលដ្ឋានរួមមានក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងមន្ទីរជំនាញ(មន្ទីរកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម) ធ្វើការជិតស្និទ្ធទៅវិញទៅមកដើម្បីធានាអោយគម្រោងនេះផ្តល់ផលប្រយោជន៍ឱ្យចំគោលដៅ និងទាន់ពេលវេលា។ អាជ្ញាធរឃុំសន្យាថានឹងយកមូលនិធិឃុំដើម្បីរួមចំណែកក្នុងការគ្រប់គ្រង និងថែទាំប្រឡាយ និងផ្លូវថ្នល់។ មន្ទីរកសិកម្មបានផ្តល់នូវការគាំទ្របច្ចេកទេសដើម្បីធានាឱ្យសហគមន៍អាចប្រើប្រាស់ ចំណេះដឹងពីវគ្គបណ្តុះបណ្តាលសម្រាប់អនុវត្តនៅក្នុងការងារផលិតកម្មកសិកម្ម ។ មន្ទីរធនធានទឹក និងឧតុនិយមបានសហការជាមួយអង្គការដើម្បីផ្តល់ការគាំទ្របច្ចេកទេសសម្រាប់ការកសាងប្រឡាយ និងសម្របសម្រួលបង្កើតគណៈកម្មការគ្រប់គ្រងប្រឡាយដើម្បីធានាតួនាទីនៃការបែងចែកទឹកស្រោចស្រព និងការដោះស្រាយទំនាស់ឱ្យបានល្អ។ អង្គការអភិវឌ្ឍន៍សហគមន៍ខ្មែរ(DKC) បានសហការយ៉ាងសកម្មក្នុងការដាំកូនឈើតាមបណ្តោយខ្នងទំនប់ក្នុងគោលបំណងដើម្បីការពារការហូរច្រោះដី និងកែលម្អបរិស្ថានក្នុងតំបន់ប្រឡាយ។ ម្យ៉ាងវិញទៀត ការសហការយ៉ាងជិតស្និទ្ធក្នុងចំណោមបុគ្គលិកអង្គការCRID អាជ្ញាធរមូលដ្ឋាន រួមទាំងមេភូមិនៃតំបន់គោលដៅ និងក្រុមប្រឹក្សាឃុំសាំងឃ្វាង បានបង្កើតជាគណៈកម្មការលទ្ធកម្មដើម្បីជ្រើសរើសអ្នកម៉ៅការដោយតម្លាភាព និងគណនេយ្យភាព។

## ២.៣ ការស្តារប្រឡាយស្រោចស្រព និងលើកផ្លូវថ្មី

ដោយសារពុំមានភ្លៀងគ្រប់គ្រាន់ ឬប្រភពទឹកហូរ ស្រះ និងទន្លេដើម្បីគាំទ្រដល់សកម្មភាពកសិកម្មគ្រួសារ ៩៧% (២៤០គ្រួសារ) ក្នុងភូមិ ល្វា ភូមិសង្កែ និងភូមិឧបមា នៃឃុំស៊ាងឃ្វាងបានប្រឈមមុខនឹងបញ្ហាសន្តិសុខស្បៀង និងខ្វះស្បៀង[8]។

ប្រឡាយរាក់ដែលមានស្រាប់មិនអាចស្តុកទឹកគ្រប់គ្រាន់សម្រាប់ការការធ្វើស្រែក្នុងអំឡុងពេលគ្រោះរាំងស្ងួតក្នុងរដូវវស្សា។ ការបន្សុំាជាមួយនឹងការអូសបន្លាយគ្រោះរាំងស្ងួតនៅក្នុងរដូវវស្សាក្នុងតំបន់គោលដៅគម្រោង ការគ្រប់គ្រងទឹកគឺជាអាទិភាពទី១ សម្រាប់ការអន្តរាគមន៍បន្ទាន់។ ការស្តារប្រឡាយគឺជាតម្រូវការអាទិភាពចំបងរបស់កសិករដើម្បីសង្គ្រោះជីវភាពរស់នៅ។

ប្រឡាយស្តារ ដែលមានប្រវែង២៤០០ម៉ែត្រ( បាតក្រោម២ម៉ែត្រ ជម្រៅ២ម៉ែត្រ មាត់ប្រឡាយលើ៥ម៉ែត្រ) ដែលផែនការគម្រោងមានត្រឹម២១០០ម៉ែត្រ ក្នុងភូមិល្វា បានស្តារឡើងវិញទាំងស្រុងនៅបំណាច់ខែមីនា ឆ្នាំ២០១២ ក្នុងគម្រោងទី១ ក្រោមការគាំទ្រពីគណៈកម្មការលទ្ធកម្មឃុំស៊ាង ឃ្វាង រួមមានបុគ្គលិកអង្គការ សមាជិកក្រុមប្រឹក្សាឃុំ គណៈកម្មការគ្រប់គ្រងប្រឡាយ និងបុគ្គលិកបច្ចេកទេសរបស់មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង(រូបភាព២)។ បន្ទាប់មកទៀតក៏មានការស្តារបន្តប្រឡាយប្រវែង ១៤០០ម៉ែត្រ ដែលមានទំហំប៉ុនគ្នា គាំទ្រដោយ UNDP/SGP/CCBAP នៅក្នុងដំណាក់កាលគម្រោងទី២។ ដូច្នេះ ប្រវែងប្រឡាយសរុប ៣៨០០ម៉ែត្រ( ភូមិល្វា និងភូមិជាខ្លាង )។



រូបភាព២: សកម្មភាពស្តារប្រឡាយក្នុងខែមីនា ឆ្នាំ២០១២

ទឹកក្នុងប្រឡាយមានសក្តានុពលអាចស្រោចស្រពបាន៣២១ ហិកតានៃស្រូវវស្សាសម្រាប់៣១៣គ្រួសារក្នុងភូមិចំនួន៥ (ល្វា សង្កែ ឧបមា ជាខ្លាង និងថ្កែកូន) នៃឃុំពីរ (ស៊ាងឃ្វាង និងជាខ្លាង)។ លើសពីនេះទៅទៀត ដីជីកពីប្រឡាយត្រូវបានកសាងជាទំនប់តាមបណ្តោយប្រឡាយទាំងសងខាង ដើម្បីគ្រប់គ្រងទឹក ។

ទំនប់បានក្លាយជាផ្លូវលំដ៏សំខាន់(រូបភាព៣) សម្រាប់អ្នកភូមិធ្វើដំណើរទៅស្រែរបស់គាត់ និងទៅកាន់ភូមិផ្សេងៗក្នុងតំបន់។ ទំនប់ (ផ្លូវ)តាមបណ្តោយប្រឡាយក៏មានតួនាទីដើម្បីស្ទាក់ទឹកដែលហូរមកពីតំបន់ខ្ពស់ផ្នែកខាងលើនៃប្រឡាយផងដែរ។ ផ្លូវនេះតភ្ជាប់រវាងឃុំស៊ាងឃ្វាង ទៅឃុំជាខ្លាងដែលបង្កលក្ខណៈងាយស្រួលសម្រាប់កសិករទៅស្រែ និងដឹកជញ្ជូនកសិផល។



រូបភាព៣: ការកសាងផ្លូវតាមបណ្តោយប្រឡាយ

8 Data from Kveang commune in 2011.

# ២.៤ បង្កើតគណៈកម្មការប្រើប្រាស់ទឹក(FWUC) និងធនាគារស្រូវ

បង្កើតគណៈកម្មការប្រើប្រាស់ទឹកគឺជាកត្តាចាំបាច់ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់និងថែទាំប្រឡាយ(O&M)តាមរយៈការប្រមូលថ្លៃឈ្នួលទឹក និងសម្បុរសធម៌ ព្រមទាំងការគ្រប់គ្រងការចែកចាយទឹក និងដំណោះស្រាយជម្លោះក្នុងចំណោមគណៈកម្មការប្រើប្រាស់ទឹកក្នុងតំបន់គម្រោង។ គណៈកម្មការប្រើប្រាស់ទឹក ត្រូវបានជ្រើសរើសឡើងដោយការបោះឆ្នោតពីភូមិចំនួន៣ រួមមានភូមិល្វា ភូមិឧបមា និងភូមិសង្កែក្រោមការសម្របសម្រួល និងការគាំទ្របច្ចេកទេស ពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង(រូបភាព៤)។គណៈកម្មការនេះបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន។ ការទទួលខុសត្រូវរបស់សមាជិកគណៈកម្មការគឺគ្រប់គ្រងនិងត្រួតពិនិត្យការស្តារប្រឡាយ ការចែកចាយទឹក និងការដោះស្រាយទំនាស់ ការដាំកូនឈើ និងដំណើរការធនាគារស្រូវ។ គណៈកម្មការប្រើប្រាស់ទឹក បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីប្រមូលថវិកាពីការប្រើប្រាស់ទឹកប្រឡាយ និងទំនប់តាមបណ្តោយប្រឡាយ និងទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំដោយមានការគាំទ្រពីអង្គការ CRID ដែលជាអ្នកទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយអភិបាលស្រុក និងមន្ទីរធនធានទឹក និងឧតុនិយមដើម្បីបង្កើតគណៈកម្មការលទ្ធកម្មដោយគណនេយ្យភាព និងតម្លាភាពក្នុងគោលបំណងដើម្បីជ្រើសរើសអ្នកម៉ៅការជីកប្រឡាយ និងសង់សំណង់ស្នាក់ទឹកក្នុងតម្លៃសមរម្យ។ សមាជិកគណៈកម្មការប្រើប្រាស់ទឹកជាក្រុមដ៏សំខាន់ ដែលមានឥទ្ធិពលចំពោះសមាជិកសហគមន៍ប្រើប្រាស់ទឹកដើម្បីស្វែងរកដំណោះស្រាយ និងការចែកចាយទឹកស្រោចស្រពដោយសមភាព ក្នុងចំណោមកសិករក្នុងតំបន់គោលដៅគម្រោង។ ម្យ៉ាងវិញទៀត ដើម្បីធានាកិច្ចការពារប្រឡាយឱ្យមានដំណើរការល្អ ជៀសផុតពីការហូរច្រោះដី ការបំផ្លាញប្រព័ន្ធអេកូឡូស៊ី ដែលនេះជាតួនាទីផ្សេងទៀតរបស់គណៈកម្មការ។ គណៈកម្មការនេះបានជម្រុញឱ្យមានការចូលរួមជាកម្លាំងពលកម្មពីសហគមន៍ ដូចជា គ្រូបង្រៀន សិស្ស អាជ្ញាធរមូលដ្ឋានសរុប ៣០០នាក់ ដើម្បីដាំកូនឈើចំនួន ១៣៥០ ដើមលើខ្នង ទំនប់ (រូបភាព៥)។

និរន្តភាពនៃការស្រោចស្រពគឺការថែទាំប្រឡាយ និងការស្តុកទុកស្រូវរបស់ធនាគារស្រូវឱ្យបានគ្រប់គ្រាន់។ គណៈកម្មការប្រើប្រាស់ទឹកត្រូវបានផ្តល់តួនាទីបន្ថែមក្នុងការគ្រប់គ្រងធនាគារស្រូវដោយទទួលខុសត្រូវលើដំណើរការគ្រប់គ្រងធនាគារស្រូវ បង្កើតលក្ខខន្តិកៈសម្រាប់ធនាគារស្រូវរួមមាន គោលការណ៍នៃការខ្ចី និងការសង ទំរង់បែបបទនៃការខ្ចី និងដំណើរការសងត្រឡប់មកវិញ។ល។ កសិករដែលប្រើប្រាស់ទឹកប្រឡាយដើម្បីធ្វើស្រែក្នុងផ្ទៃដី១ហិកតា ត្រូវបង់ថ្លៃឈ្នួលជាស្រូវចំនួន ៥គក្រ ក្រោយប្រមូលផលទៅធនាគារស្រូវ ហើយពូជស្រូវនេះនឹងរក្សាទុកសម្រាប់អ្នកខ្ចីក្រោយៗទៀត (រូបភាព៦)។

នៅពេលចាប់ផ្តើម គម្រោងបានផ្តល់ពូជស្រូវចំនួន ១.០៩៣ គ.ក្រ សម្រាប់ដំណើរការធនាគារស្រូវ។ សម្រាប់ការខ្ចីស្រូវជាលើកដំបូង សហគមន៍អាចខ្ចីពូជស្រូវសុទ្ធដោយគ្មានការប្រាក់ ដោយសារតែគណៈកម្មការមានបំណងលើកទឹកចិត្តឱ្យសហគមន៍ប្រើប្រាស់ពូជស្រូវថ្មី (សែនពិដោរ ផ្ការំដួល និងអ៊ីអែ៦៦)។វិធីសាស្ត្រនេះមិនត្រឹមតែ



រូបភាព៤:ការជ្រើសរើស FWUC ដោយសហគមន៍



រូបភាព៥: ការដាំកូនឈើតាមខ្នងប្រឡាយថ្មី

អនុវត្តនៅក្នុងសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តនៅក្រៅសហគមន៍ផងដែរដើម្បីធានាការប្រើប្រាស់ពូជស្រូវអោយបានគ្រប់គ្រាន់នៅក្នុងឃុំទាំងមូល។ បច្ចុប្បន្ន ពូជស្រូវមិនសុទ្ធ១០០%នោះទេ ពីព្រោះអ្នកខ្ចីមិនមានបទពិសោធន៍ក្នុងការបន្សុទពូជ ហើយដំណើរការធនាគារស្រូវបានយកការប្រាក់ចំនួន២%។ ដូច្នេះពូជស្រូវដែលបានផ្តល់ទៅធនាគារស្រូវ បានប្រើប្រាស់សម្រាប់តួនាទីច្រើនយ៉ាង ដូចជាលក់ដើម្បីបានប្រាក់ទៅថែទាំ និងជួសជុលប្រឡាយ(O&M), ការប្រើប្រាស់ទឹក និងការថែទាំផ្លូវថ្នល់ជាដើម។ កសិករមួយចំនួនទៀតបានខ្ចីស្រូវពីធនាគារស្រូវទៅលក់ ដើម្បីយកលុយទៅទិញពូជស្រូវដែលសុទ្ធល្អសម្រាប់ដាំដុះ។ ឥឡូវនេះ ស្រូវក្នុងធនាគារបានកើនឡើងរហូតដល់ ១.៤១៤ ត.ក្រ។


រូបភាព៦: ពូជស្រូវរក្សាទុកក្នុងធនាគារស្រូវសម្រាប់ អ្នកខ្ចីបន្ត

# ២.៥ ការបង្កើតក្រុមសន្សំប្រាក់

ការបង្កើតក្រុមសន្សំ គឺជាយន្តការមួយទៀតដើម្បីធានាបាននូវស្ថេរភាពជីវភាព និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍គោលដៅ។ ក្រុមសន្សំចំនួន ៤ ដែលក្នុង១ក្រុមមានសមាជិក២០នាក់(រូបភាព៧)។ គណៈកម្មការក្រុមសន្សំត្រូវបានជ្រើសរើសដោយការបោះឆ្នោតពីអ្នកភូមិ និងបានទទួលស្គាល់ដោយក្រុមប្រឹក្សាឃុំ។ វគ្គបណ្តុះបណ្តាលចំនួន៤ ស្តីពីវិធីសាស្ត្រនៃការខ្ចី ការសន្សំ និង ដំណើរការសងត្រឡប់ បានផ្តល់ទៅដល់គណៈកម្មការសហគមន៍ និងសមាជិក៩០នាក់ (ស្រី៦៤នាក់)។ នៅពេលចាប់ផ្តើម គម្រោងបានផ្តល់ប្រាក់ចំនួន ២.០០០ដុល្លារ ទៅក្រុមសន្សំប្រាក់ទាំងបួន(ក្រុមនីមួយៗទទួលបាន៥០០ដុល្លារ) រួមមានក្រុមក្នុងភូមិល្វា ឧបមា ដូនយូ និងព្រៃឬស្សីក្នុងខែមករា ឆ្នាំ២០១៣ ដោយប្រាក់សន្សំបន្ថែមពីក្រុមចំនួន៥៦៨ដុល្លារ។ ជាមួយគ្នានេះផងដែរ ក្រុមសន្សំ កើនប្រាក់ដល់ ២៥៦៨ ដុល្លារ នៃមូលនិធិសរុប ហើយការប្រាក់សរុបគឺ៣៥៦ ដុល្លារ ទាំងមកពីគម្រោង និងការចូលរួមមូលនិធិផ្ទាល់ខ្លួន។ ជាមួយវិធីសាស្ត្រនេះ គេបានសង្កេតឃើញថាជីវភាពរស់នៅរបស់ប្រជាជនបានប្រសើរគួរអោយកត់សំគាល់សម្រាប់អ្នកភូមិ ដែលបានចូលរួមក្នុងក្រុមនេះ ដែលធ្វើអោយពួកគាត់អាចជៀសផុតពីបំណុលដែលបានខ្ចីពីធនាគារមីក្រូហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ខ្ពស់ក្នុងតំបន់គោលដៅរបស់គាត់។ មាន ៥គ្រួសារបានខ្ចីប្រាក់ពីក្រុមសន្សំ សម្រាប់ចិញ្ចឹមមាន់មេ(០៨មេមាន់) និង១១គ្រួសារទៀតសម្រាប់ចិញ្ចឹមជ្រូក(១១ក្បាល)។


រូបភាព៧: ការបង្កើតក្រុមសន្សំប្រាក់

# ២.៦ ការពង្រឹងសមត្ថភាព និងការផ្តល់សិទ្ធអំណាចដល់សហគមន៍

វគ្គបណ្តុះបណ្តាលចំនួន៣ថ្ងៃ ស្តីពីការគ្រប់គ្រងប្រឡាយ និងធនាគារស្រូវ បានផ្តល់ដល់គណៈកម្មការប្រើប្រាស់ទឹក។ វគ្គនេះផ្តោតសំខាន់លើវិធីសាស្ត្រ និងយន្តការរួមបញ្ចូលទាំងការគ្រប់គ្រង និងការថែទាំ ការប្រមូលថ្លៃប្រើប្រាស់ទឹក ការចូលរួមកៀរគរជំនួយ ការរៀបចំទីកន្លែងទុកដាក់ និងការបែងចែកគ្រាប់ពូជឱ្យបានសមស្រប ដំណើរការសងពូជស្រូវត្រលប់មកវិញ និងការធ្វើរបាយការណ៍ពីកម្ចីពូជរបស់ធនាគារស្រូវ (រូបទី៨)។ល។ វគ្គបណ្តុះបណ្តាលចំនួន ១០វគ្គ (បីថ្ងៃក្នុង១វគ្គ) លើបច្ចេកទេស បវស បានផ្តល់ដល់អ្នក ចូលរួមសរុប ២៦៦នាក់ (ស្រី១៨៣នាក់) មកពី១៣ភូមិ ក្នុងឃុំសាំង ឃ្វាង លើវិធីសាស្ត្រ នៃអនុវត្តបច្ចេកទេសថ្មី និងការជ្រើសរើសពូជដែលធន់ និងអាចផ្តល់នូវទិន្នផលខ្ពស់ហើយតម្រូវការទឹកតិច (រូបភាព៩)។ គម្រោងនេះបានផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលលើពិធីសារ បវស និងបានជ្រើសរើសកសិករគំរូ ចំនួន៤០នាក់ ដើម្បីអនុវត្តចំណេះដឹងនេះ។ បវសអាចផ្តល់ទិន្នផលខ្ពស់ជាងវិធីសាស្ត្រប្រពៃណី។ វិធីសាស្ត្របច្ចេកទេសកសិកម្មទាំងនេះ គឺសមស្របសម្រាប់អនុវត្តក្នុងតំបន់គោលដៅនេះដែលជាតំបន់ប្រឈមនឹងកាលៈទេសៈនៃការប្រែប្រួលអាកាសធាតុ ពិសេសគ្រោះរាំងស្ងួតដែលមានរយៈពេលវែង។ ការអនុវត្តបច្ចេកទេសនេះកសិករអាចប្រើប្រាស់ពូជស្រូវ ១៥ ទៅ ២០គក្រ ក្នុង១ហិកតា និងអាចបង្កើនការដាំដុះដំណាំស្រូវបាន២ដងក្នុង១ឆ្នាំ។ ទោះបីយ៉ាងណាក៏ដោយ មានតែកសិករនៅក្នុងភូមិល្វា អាចអនុវត្តវិធីសាស្ត្រ បវស ដោយសារពួកគាត់មានដីស្រែតូចៗ ខណៈភូមិផ្សេងៗមិនអាចអនុវត្តបានដោយសារមានដីស្រែធំៗ (២ទៅ៣ ហិកតា) និងស្រែទឹកជម្រៅ។ ហេតុដូច្នេះ វិធីសាស្ត្រនេះបានអនុវត្តជាមួយកសិករដែលមានកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់ការដាំដុះ បវស តែប៉ុណ្ណោះ។



រូបភាព ៨: ការអប់រំផ្សព្វផ្សាយអំពីការគ្រប់គ្រងធនាគារស្រូវដល់ FWUC





រូបភាព៩: វគ្គបណ្តុះបណ្តាលស្តីពីបវស និងការធ្វើស្រែបង្ហាញ

# ៣. សមិទ្ធផលបណ្ដោះអាសន្ន និងលទ្ធផល

## ៣.១ ធ្វើឱ្យប្រសើរឡើងនៃការដាំដុះដំណាំស្រូវតាមរយៈការស្ដារប្រឡាយ

ប្រឡាយប្រវែង ៣៨០០ម៉ែត្រ ត្រូវបានស្ដាររួចរាល់ ដោយជោគជ័យ (រូបភាព១០) ។ ប្រឡាយនេះមានតួនាទីជាប្រឡាយប្រមូលទឹក និងរក្សាទឹកដើម្បីស្រោចស្រពដីស្រែអំឡុងពេលរាំងស្ងួតដែលអូសបន្លាយនៅក្នុងរដូវវស្សា ដោយមានសមត្ថភាពស្តុកទឹករហូតដល់ ២៥.០០០ម៉ែត្រគូប។

នៅផ្នែកខាងលើ នៃប្រឡាយចំងាយប្រមាណ២០៥០ម៉ែត្រ មានបឹងមួយមានទំហំទទឹង ២៥០ម៉ែត្រ និងបណ្ដោយ ១០០០ម៉ែត្រ និងជម្រៅ១ម៉ែត្រ។ បឹងនេះគឺជាប្រភពទឹកដ៏សំខាន់សម្រាប់ផ្គត់ផ្គង់ទឹកទៅប្រឡាយដើម្បីផ្ដល់ទឹកបន្ថែមដល់ការស្រោចស្រពដីស្រែក្នុងតំបន់នោះ ជាពិសេសនៅចុងរដូវវស្សា។ លើសពីនេះទៅទៀត ទីតាំងនៃប្រឡាយស្ថិតនៅផ្នែកខាងក្រោមបឹងនេះជាឱកាសល្អសម្រាប់ប្រឡាយទទួលបានទឹកកាន់តែច្រើនពីបឹង។ ទំនប់អមសងខាងប្រឡាយក៏មានតួនាទីគ្រប់គ្រង និងរក្សាទឹក សម្រាប់ដីស្រែដែលមានទីតាំងស្ថិតនៅភាគខាងលើឱ្យមានទឹកគ្រប់គ្រាន់សម្រាប់ការដាំដុះដំណាំស្រូវ នៅក្នុងដើមរដូវវស្សា និងអំឡុងពេលការអូសបន្លាយគ្រោះរាំងស្ងួតនៅក្នុងរដូវវស្សា។ ប្រឡាយ និងទំនប់បានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងទឹកក្នុងស្រែដែលមានទីតាំងនៅផ្នែកខាងលើនៃប្រឡាយសម្រាប់ភាពធន់ទៅនឹងគ្រោះរាំងស្ងួតពេលមានការអូសបន្លាយ ក្នុងរដូវវស្សាអំឡុងពេលស្រូវកំពុងលូតលាស់។ ម្យ៉ាងទៀត ប្រឡាយនេះបានភ្ជាប់ទៅនឹងប្រឡាយមេឆ្លងកាត់ស្រុកដែលជាប្រភពទឹកសំខាន់ពីប្រឡាយដែលបានកសាងឡើងដោយក្រសួងធនធានទឹក និងឧតុនិយម។ ប៉ុន្ដែបញ្ហាប្រឈមពីការទទួលបានទឹកពីប្រឡាយថ្នាក់ស្រុកនេះគឺ សហគមន៍ចាំបាច់ត្រូវប្រើម៉ាស៊ីនបូមទឹក ព្រោះប្រឡាយនេះមាននីវ៉ូទឹកទាបជាងប្រឡាយដែលទើបនឹងស្ដារនៅឃុំ។

ប្រឡាយនេះបានសាងសង់សំណង់សិល្បៈការដូចជាទ្វារស្នាក់ទឹក និងស្ពានផងដែរដើម្បីបង្វែរទឹក និងដើម្បីរក្សាកម្រិតទឹក និងចែកចាយលំហូរទឹកពីប្រឡាយទៅដីស្រែ។ ប្រឡាយនេះបានផ្ដល់នូវក្ដីសង្ឃឹមថ្មីសម្រាប់កសិករដើម្បីកែលម្អជីវភាព ដោយសារមានទឹកគ្រប់គ្រាន់សម្រាប់ការធ្វើស្រែនៅក្នុងរដូវវស្សា និងអាចបង្កើនការធ្វើស្រែនៅដើមរដូវវស្សាបានចំនួន៣៣ហិកតា និងចុងរដូវវស្សាបាន២៦ហិកតាខណៈដែលពីមុនវាលស្រែទាំងនេះធ្វើបានតែក្នុងរដូវវស្សាតែមួយដងគត់។





រូបភាព១០: ប្រឡាយផ្ទុសផុលថ្មីដើម្បីកែលម្អការគ្រប់គ្រងទឹកសម្រាប់ស្រោចស្រពដំណាំស្រូវដែលស្ថិតនៅតាមបណ្ដោយប្រឡាយទាំងសងខាង





រូបភាព១១: ប្រឡាយថ្មីផ្តល់ការស្រោចស្រពទឹកដើម្បីបង្កើនការដាំដុះដំណាំស្រូវតាមបណ្តោយទាំងសងខាងនៃប្រឡាយ អំឡុងពេលការអូសបន្លាយនៃគ្រោះរាំងស្ងួតនៅរដូវវស្សា

មុនពេលដែលគម្រោងអនុវត្ត កសិករនៅតំបន់គោលដៅធ្វើស្រែតែមួយដងទេ(៣២០ហត) គឺនៅខែ កក្កដា ពាក់កណ្តាលរដូវវស្សា ដូចនេះ កសិករត្រូវរង់ចាំរហូតដល់មានទឹកគ្រប់គ្រាន់ក្នុងស្រែ។ ហើយជាញឹកញាប់ កសិករតែងតែប្រឈមនឹងការអូសបន្លាយគ្រោះរាំងស្ងួតក្នុងរដូវវស្សា។ ក្រោយពីគម្រោងបានអនុវត្តមានកសិករចំនួន៦០គ្រួសារដែលមានផ្ទៃដីប្រហែល ៥៣ហត នៅសងខាងប្រឡាយនៅក្នុងភូមិល្វាអាចយកទឹកមកប្រើប្រាស់សម្រាប់សង្គ្រោះស្រូវក្នុងគ្រាដែលមានការអូសបន្លាយគ្រោះរាំងស្ងួតដែលបានកើតឡើងនៅក្នុងរដូវវស្សា(ចុងខែកក្កដា ដើមខែសីហា)។ តាមរយៈគម្រោងប្រព័ន្ធស្រោចស្រពនេះ កសិករអាចចាប់ផ្តើមបង្កបង្កើនផលលើកទី១នៅខែ ឧសភា លើកទី២ នៅខែសីហា និង លើកទី៣ នៅដើមខែវិច្ឆិកា ដោយបូមទឹកពីប្រឡាយបញ្ចូលស្រែ(រូបភាពទី១១)។

ក្រោយពីគម្រោងបានបញ្ចប់ គេសង្កេតឃើញថាមានកសិករខ្លះ (២០ទៅ៣០គ្រួសារ) ដែលមានស្រែនៅជិតប្រឡាយអាចបង្កបង្កើនផលបាន៣ដង ក្នុងមួយឆ្នាំបើប្រៀបធៀបទៅនឹងមុនអនុវត្តគម្រោង កសិករមិនមានជំនឿក្នុងការធ្វើស្រែសូម្បីតែមួយដងក្នុងមួយឆ្នាំ។

តារាង១៖ ការផ្លាស់ប្តូរសកម្មភាពធ្វើស្រែមុន និងក្រោយពេលអនុវត្តគម្រោង

| អនុវត្តកសិកម្ម | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ |
|---|---|---|---|---|---|---|---|---|---|---|
| មុនមានគម្រោង | | | ស្រូវរយៈពេលវែង | | | | | | | |
| មុនមានគម្រោង | ដើមរដូវវស្សា | | ពាក់កណ្តាលរដូវវស្សា | | | ចុងរដូវវស្សា | | | | |

មុនពេលដែលគម្រោងអនុវត្តកសិករនៅតំបន់គោលដៅ(៣២០ហត)ធ្វើស្រែតែមួយដងទេគឺចាប់ផ្តើមនៅខែកក្កដា(ពាក់កណ្តាលរដូវវស្សា) ដូចនេះគេត្រូវចាំរហូតដល់មានទឹកគ្រប់គ្រាន់ទើបដាំដុះ។

## ៣.២ ការពង្រឹងសមត្ថភាពលើទស្សនៈទានការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនាគារស្រូវ ប្រឡាយនិងបច្ចេកទេសកសិកម្ម

ការពង្រឹងសមត្ថភាពរួមមានគណៈកម្មការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងធនាគារស្រូវ ការជ្រើសរើសកសិករដើម្បីអនុវត្តបច្ចេកទេសកសិកម្មបានផ្តល់ទៅឱ្យអ្នកទទួលផលនៅក្នុងតំបន់គោលដៅ ដែលវាអាចជួយបង្កើនការផ្តួចផ្តើមគំនិត និងភាពជាម្ចាស់ការលើខ្លួនឯងរបស់កសិករផងដែរ។ គណៈកម្មការប្រើប្រាស់ទឹក(FWUC) មានតួនាទីចម្បង ពីរ គឺគ្រប់គ្រងការប្រើប្រាស់ និងថែទាំប្រឡាយ និងការគ្រប់គ្រងធនាគារស្រូវឱ្យមានប្រសិទ្ធិភាព ដោយមានការគាំទ្រដំសកម្មពីក្រុមប្រឹក្សាឃុំស៊ាងឃ្វាង។ សហគមន៍អាចមានសមត្ថភាពក្នុងការពង្រឹងការសាមគ្គីភាពគ្នា ដែលអាចកំណត់អំពីហានិភ័យនានាបណ្តាលមកពីការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍ និងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីគម្រោង។ ហេតុដូចនេះ កសិករអាចបង្កើនប្រាក់ចំណូលតាមរយៈ ការអនុវត្តន៍នូវបច្ចេកទេសកសិកម្ម ជាពិសេសគឺវិធីសាស្ត្រក្នុងការជ្រើសរើសពូជ ដែលផ្តល់ទិន្នផលខ្ពស់ (ច្រើនជាង ៣តោន/ហត) ហើយអ្នកទទួលផលមានទឹកគ្រប់គ្រាន់ពីប្រឡាយដើម្បីយកទៅស្រោចស្រពដីស្រែ ដែលអាចបន្សាំនឹងភាពរាំងស្ងួតក្នុងរដូវវស្សា។

## ៣.៣ ភាពជោគជ័យលើការគ្រប់គ្រងធនាគារស្រូវ ការថែទាំ និងប្រើប្រាស់ប្រឡាយ

សមិទ្ធិផលជាច្រើនត្រូវបានផលិតឡើងដោយយន្តការ នៃសហគមន៍កសិករប្រើប្រាស់ទឹកក្រោមការគាំទ្រផ្នែកបច្ចេកទេស និងការងាររដ្ឋបាលពីមន្ទីរធនធានទឹក និងឧតុនិយម មន្ទីរកសិកម្ម អាជ្ញាធរមូលដ្ឋាន និងបុគ្គលិកគម្រោងក្នុងតំបន់គោលដៅ។ គណៈកម្មការលទ្ធកម្ម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍ បានជ្រើសរើសអ្នកម៉ៅការដ៏មានប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព ចំពោះការចំណាយក្នុងការស្តារប្រឡាយនេះ។ ជាលទ្ធផលថវិកាដែលបានចំណាយលើការស្តារប្រឡាយគឺតិចជាងការប៉ាន់ស្មាន និងសំរេចបានលើសគោលដៅពី ២១០០ ទៅ ២៤០០ ម៉ែត្រសម្រាប់គម្រោងទីមួយ និងគម្រោងទីពីរបានស្តារបន្ថែម១៤០០ម៉ែត្របថែមទៀត។ ដូចនេះប្រវែងប្រឡាយសរុបទាំងអស់មាន ៣៨០០ ម៉ែត្រ។ ថវិកានៅសល់ពីការដេញថ្លៃត្រូវបានយកទៅបំពេញបន្ថែមលើការកសាងសង់ផ្លូវដែលជាសកម្មភាពមិនត្រូវបានគេកំណត់ជាគោលដៅក្នុងគម្រោងនេះ។ក្រោមការអន្តរាគមន៍ពីគណៈកម្មការគ្រប់គ្រងប្រឡាយ មានការចូលរួមគាំទ្រជាកម្លាំងពលកម្ម និងសម្ភារៈពីកសិករ ក្នុងការកសាងផ្លូវនេះ ដែលធ្វើឱ្យគម្រោងនេះបានឈានដល់ការទទួលបានជោគជ័យបន្ថែមទៀត។

សមធម៌លើការបែងចែកទឹកបានកើតឡើង ហើយជម្លោះលើដីស្រែប្រវែង ៣០០ម៉ែត្រ របស់ ២គ្រួសារ នៅជាប់ប្រឡាយត្រូវបានដោះស្រាយតាមរយៈការអន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ និងមន្ទីរធនធានទឹក និងឧតុនិយម។ លើសពីនេះទៀត គេសង្កេតឃើញថាមានការកែលម្អជីវភាពរស់នៅមិនត្រឹមតែកសិករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកខ្លួនឯងផងដែរ តាមរយៈមានទឹកស្រោចស្រពពីប្រឡាយ។ គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកបានធ្វើការត្រួតពិនិត្យតាមដាន និងការវាយតំលៃការប្រើប្រាស់ប្រឡាយ និងផ្លូវ យ៉ាងទៀងទាត់។ ប្រសិនបើវាមានបញ្ហា ពួកគេបានចាត់វិធានការយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន ក្នុងការដោះស្រាយបញ្ហា។ ឧទាហរណ៍នៅក្នុងការអនុវត្តជាក់ស្តែង មិនអនុញ្ញាតឱ្យគោឬក្របីឆ្លងកាត់ទំនប់នៅរដូវវស្សាទេ ប៉ុន្តែអាចធ្វើទៅបានសម្រាប់ការជិះកង់។ វិធីសាស្រ្តមួយផ្សេងទៀត FWUC បានអំពាវនាវឱ្យមានការប្រជុំបន្ទាន់ជាមួយអាជ្ញាធរឃុំ និងការកៀរគរថវិកាពីឃុំ និងសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីថែទាំទំនប់ប្រឡាយ ខណៈដែលមានទឹកហូរកាត់យ៉ាងជន់ជោរ លើទំនប់ប្រឡាយ។ សមាជិកសហគមន៍កសិករប្រើប្រាស់ទឹក បានចូលរួមជាសម្ភារៈ និងបង់ថ្លៃទឹកដើម្បីជួសជុលទំនប់តាមបណ្តោយប្រឡាយឡើងវិញ នៅពេលដែលវាត្រូវបានបំផ្លាញ ហើយក៏ដើម្បីធានាឱ្យមានដំណើរការគ្រប់គ្រង និងការថែទាំប្រឡាយ តាមរយៈធនាគារស្រូវក្នុងការប្រមូលថវិកាដើម្បីជួសជុលប្រឡាយផងដែរ។ កសិករមានឆន្ទៈក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងវិស័យអភិវឌ្ឍន៍ ឃុំ នៃការងារអភិបាលកិច្ចមូលដ្ឋាន និងសម្រាប់កសិករដែលមានបំណងចូលរួមចំណែកដោយសារតែកសិករអាចទទួលបានផលប្រយោជន៍ពីប្រឡាយ និងលក្ខខណ្ឌផ្លូវដ៏ល្អ (ខ្នងទំនប់ប្រឡាយ) សម្រាប់ការធ្វើដំណើរ និងសន្សំសំចៃពេលវេលាបានប្រហែល១ម៉ោងក្នុងការធ្វើដំណើរទៅស្រែ និងកាត់បន្ថយការចំណាយលើការធ្វើដំណើរសម្រាប់ដឹកកសិផល និងសម្ភារៈកសិកម្មដទៃទៀត។ លើសពីនេះទៅទៀតវាជាផ្លូវកាត់ និងការតភ្ជាប់ទំនាក់ទំនងផ្លូវតមនាគមន៍ទៅកាន់ស្រុកស្វាយអន្ទរផងដែរ ក្នុងការនាំយកផលិតផលកសិកម្មរបស់ខ្លួនទៅកាន់ទីផ្សារ។ ការគ្រប់គ្រងទឹកគឺជាផ្នែកដ៏សំខាន់មួយនៃការដាំដុះកសិកម្មដែលមានភាពធន់ទៅនឹងការអូសបន្លាយគ្រោះរាំងស្ងួតនៅក្នុងរដូវវស្សា ប៉ុន្តែពូជស្រូវគឺជាការបន្ស៊ាំដែលមានភាពធន់ដ៏សំខាន់មួយទៀតដែលស្របទៅនឹងការគ្រប់គ្រងទឹក និងមិនអាចមើលរំលងក្នុងគោលបំណងដើម្បីជីវភាពប្រសើរឡើងជាងមុននៅក្នុងតំបន់គោលដៅ។ ការប្រើប្រាស់យន្តការធនាគារស្រូវគឺត្រូវការចាំបាច់នៅក្នុងតំបន់ងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុដើម្បីធានាថាកសិករមានពូជគ្រប់គ្រាន់ បើទោះបីជាត្រូវប្រឈមមុខទៅនឹងគ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់ក៏ដោយ។ មុនពេលដែលគម្រោងនេះចាប់ផ្តើម ពុំមានការផ្តួចផ្តើមបែបនេះនោះទេ។ កសិករត្រូវការចំណាយថវិកាច្រើនលើការទិញគ្រាប់ពូជស្រូវសម្រាប់ដាំដុះ។ ទោះជាយ៉ាងណាបន្ទាប់ពីការបង្កើតធនាគារស្រូវកសិករមិនចាំបាច់ទិញគ្រាប់ពូជពីខាងក្រៅទេ ដោយសារកសិករ អាចខ្ចីស្រូវពូជពីធនាគារស្រូវនេះជាមុន។ បន្ទាប់ពីការប្រមូលផល ពួកគេបានសងគ្រាប់ពូជត្រឡប់មកវិញដើម្បីរក្សាទុកសម្រាប់អ្នកខ្ចីបន្ទាប់។ ធនាគារស្រូវអាចនឹងដំណើរការបានយ៉ាងល្អដោយសារមានយន្តការដ៏សំខាន់ពីរ មួយគឺចំណេះដឹងរដ្ឋបាល និងវិធីសាស្រ្តគ្រប់គ្រងរបស់គណៈកម្មការការគ្រប់គ្រង និងមួយផ្សេងទៀត គឺជាការទទួលស្គាល់ ជាផ្លូវការរបស់ធនាគារដោយក្រុមប្រឹក្សាឃុំ។ មាន ២៣១ គ្រួសារមកពីឃុំស៊ាងឃ្វាង និង ឃុំជាខ្លាងបានចូលរួមនៅក្នុងដំណើរការធនាគារស្រូវ និងពូជស្រូវបានកើនឡើងពី ៣២៩៣គីឡូក្រាម ទៅ ៤០៥៨ គីឡូក្រាមនៅចុងបញ្ចប់នៃរយៈពេលអនុវត្តគម្រោងនៅអំឡុងខែវិច្ឆិកា ឆ្នាំ២០១៣ ។ វិធីសាស្រ្តនេះ មិនត្រឹមតែមានប្រយោជន៍សម្រាប់តំបន់គោលដៅរបស់គម្រោងនោះទេ ប៉ុន្តែថែមទាំងមានប្រយោជន៍សម្រាប់ភូមិដទៃទៀតនៅក្នុងឃុំនេះផងដែរ។

# ៣.៤ ជីវភាពបានកែលម្អប្រសើរឡើងបន្ទាប់ពីការអនុវត្តគម្រោង

គម្រោងបានកែលម្អជីវភាពរស់នៅរបស់កសិករក្នុងតំបន់គោលដៅ ដោយធ្វើឱ្យមានការផ្លាស់ប្តូរនូវការអនុវត្តន៍ការងារកសិកម្ម (ជាទម្លាប់កសិករធ្វើស្រែតែ១ដង/ឆ្នាំ)។ កសិករនៅក្នុងតំបន់ជាទូទៅអនុវត្តការធ្វើស្រែតាមបែបប្រពៃណីដែលមិនអាចបន្សាំទៅនឹងស្ថានភាពប្រែប្រួលនៃអាកាសធាតុនាពេលបច្ចុប្បន្ន។ ជាលទ្ធផល ពួកគាត់បានប្រឈមទៅនឹងកម្រិតជីវភាពរស់នៅទាប[9]។ ការស្តារប្រឡាយបានធ្វើឱ្យតំបន់នេះមានភាពខុសគ្នា ដោយធ្វើឱ្យដីស្រែដែលស្ថិតនៅតាមបណ្តោយប្រឡាយត្រូវបានកែលម្អ ដោយទទួលបានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែ និងមានការផ្លាស់ប្តូរសកម្មភាពធ្វើស្រែ (ដើមរដូវវស្សា ពាក់កណ្តាល និងចុងរដូវវស្សា។ ការគ្រប់គ្រងទឹកនៅក្នុងប្រឡាយបានបង្កើនសំណើមដីជុំវិញប្រឡាយ និងការផ្លាស់ប្តូរទំរង់ដីសម្រាប់សហគមន៍ដើម្បីមានឱកាសដាំដុះដំណាំដែលត្រូវការទឹកតិច ដូចជាឪឡឹក ឬត្រសក់នៅដើមរដូវប្រាំង បន្ទាប់ពីការប្រមូលផលស្រូវនៅខែធ្នូ)។ លើសពីនេះទៀតដោយមានការគាំទ្រពីធនាគារស្រូវនៅលើការខ្ចីពូជស្រូវ ក្រុមសន្សំ និងការអនុវត្តវិធីសាស្ត្រ ប.វ.ស (SRI) កសិករអាចបង្កើនផលិតកម្មស្រូវដោយមានតម្លៃសមរម្យអាចទទួលយកបាន និងការយល់ដឹងថា ប.វ.ស គឺជាវិធីសាស្ត្រល្អមួយដើម្បីបន្សុទ្ធពូជស្រូវ។ ពួកគេអាចប្រើពូជស្រូវប្រហែល ១៥-២០ គីឡូក្រាមក្នុងមួយហិកតា លើសពីនេះទៅទៀត ស្រូវរដូវប្រាំងរបស់កសិករពី ១៥ ទៅ ១៧ គ្រួសារនៅក្នុងភូមិល្វា (មានដីស្រែប្រហែល ១ ហិកតាក្នុងមួយគ្រួសារ) បានផលិតស្រូវជាមធ្យមពី ៣ តោនក្នុងមួយហិកតា។ គួរឱ្យកត់សម្គាល់, ៧គ្រួសារ ក្នុងចំណោម ២០ គ្រួសារដែលបានអនុវត្ត ប.វ.ស ទទួលបានផលអតិបរមារហូតដល់ទៅ ៤ តោនក្នុងមួយហិកតា បើប្រៀបធៀបទៅនឹងឆ្នាំមុនទទួលបានត្រឹមតែ ២,៦ តោនក្នុងមួយហិកតា ។ ទោះបីយ៉ាងណាក៏ដោយ បវស គឺសមស្របសម្រាប់ដីស្រែដីតូចប៉ុណ្ណោះ ព្រោះបច្ចេកទេស ប.វ.ស នេះត្រូវការកម្លាំងពលកម្មច្រើន។

នៅដើមរដូវវស្សា ដីប្រមាណ១៥ហិកតាអាចដាំដុះដោយប្រើប្រាស់ទឹកបន្ថែមដែលបានពីប្រឡាយស្រោចស្រពនេះ។ នៅចុងរដូវវស្សា កសិករក៏អាចធ្វើស្រែបានប្រហែល១០-១៥ ហិកតា ផងដែរ។ ជាទូទៅ កសិករអាចប្រមូលផលស្រូវបានប្រហែល ៤តោន ក្នុងមួយហិកតាដោយបានចំណាយលើផលិតកម្មសរុបជាមធ្យម ៥០០ដុល្លារអាមេរិក/ហិកតា (តារាង ២) ។ ដូច្នេះកសិករអាចរកប្រាក់ចំណូលបានចន្លោះពី ២៥០-៣៥០ ដុល្លារអាមេរិក / ហិកតា (ប្រសិនបើ ១ គីឡូក្រាមស្រូវ ០,២ ដុល្លារ ឬ ៨០០ រៀល) ។ ប្រឡាយស្តារថ្មីនេះអាចបង្កើតប្រាក់ចំណេញពីការធ្វើស្រែដើម និងចុងរដូវវស្សារវាង ៧០០០-១០០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ (បានមកពីការបង្កើនការធ្វើស្រែ នៅដើម និងចុងរដូវវស្សា លើផ្ទៃដីពី ២០-៣០ ហិកតា) ។ ប្រសិនបើគិតបញ្ចូលទាំងតម្លៃសង្គ្រោះស្រូវវស្សាក្នុងអំឡុងពេលរដូវវស្សាដែលប្រឡាយអាចជួយសង្គ្រោះបានប្រមាណ ២០០ហិកតា និង ៣០០ ហិកតាក្នុងតំបន់គោលដៅនោះការវិនិយោគគម្រោងការស្តារប្រឡាយនេះគឺជាការចំណាយដ៏មានប្រសិទ្ធភាពសម្រាប់ការបន្សាំនៅសហគមន៍។




រូបភាព១២: ការធ្វើស្រែរដូវប្រាំងដោយប្រើប្រាស់ទឹកស្រោចស្រពពីប្រឡាយ(១០-១៥ហិកតា)

9 CRID, 2011. Full proposal on "Community's capacity improvement for adaptation to climate change in Seang Kveang, Kamchay Mear district, Prey Veng province".

តារាងទី២: តម្លៃមធ្យមនៃផលិតកម្មស្រូវ(ការកើនឡើងរយៈពេល ៣-៤ ខែ) ដោយផ្អែកលើលទ្ធផលនៃក្រុមពិភាក្សា

| បរិយាយ | ការចំណាយថ្លៃដើមសម្រាប់ផលិតកម្មស្រូវក្នុង ១ហិកតា គិតជាដុល្លារអាមេរិក | សំគាល់ |
|---|---|---|
| ការរៀបចំដី | ៧៥ | ម៉ាស៊ីនភ្ជួរដី និងថ្លៃពលកម្មត្រឹមតែ១ដង/ដំណាំ |
| ពូជ (រំដួល,សែនពិដោរ) | ៥០ | ២០០ គ.ក/ហ.ត<br>( វិធីសាស្ត្រព្រួសគ្រាប់ តាមបែបប្រពៃណី ) |
| ជីគីមី | ១៥០ | ៣០ដុល្លារ/បាវ ( ៥បាវ/ ហ.ត ) |
| ថ្នាំសម្លាប់ស្មៅ | ១០ | ៤បាវ/ ហ.ត |
| ប្រេងឥន្ធនៈសម្រាប់បូមទឹក | ៦៥ | ១.៥កាន/ហ.ត ( ១កាន=៣០លីត្រ ) |
| ប្រមូលផល | ៧៥ | ម៉ាស៊ីនច្រូតស្រូវ និងឈ្នួលកម្មករ |
| ថ្លៃកំលាំងពលកម្ម | ៥០ | ព្រួស ជី និង ការងារបាញ់ស្មៅ បូមទឹក ។ល។ |
| ចំណាយផ្សេងៗ | ២៥ | ថ្លៃធ្វើដំណើរក្នុងស្រុក ឈ្នួលទឹក និងផ្សេងៗ |
| សរុប | ៥០០ | សរុបថ្លៃផលិតកម្មស្រូវ/ហ.ត |

ផ្លូវលំថ្មីមួយខ្សែប្រវែង ៤ គីឡូម៉ែត្រ ( ទទឹង ៣ ម៉ែត្រ ) ត្រូវបានកសាងឡើងបន្ទាប់ពីការស្តារប្រឡាយ (រូបភាពទី១៣) ដែលអាចភ្ជាប់ទៅផ្លូវមួយផ្សេងទៀតនៅចុងនៃប្រឡាយ និងមានភាពងាយស្រួលក្នុងការធ្វើដំណើររបស់កសិករទៅកាន់ទៅដីស្រែរបស់ខ្លួន (មិនកំណត់ថាជា សូចនាករនៃគម្រោងនេះទេ)។ មុនពេលដែលគម្រោងនេះចាប់ផ្តើមកសិករបានចំណាយពេលវេលាចេញទៅស្រែ និងត្រឡប់មកវិញយ៉ាងហោចណាស់ ៣០នាទីពីផ្ទះ ព្រោះធ្វើដំណើរតាមភ្លឺស្រែមានការលំបាកដោយសារការក្នុងការដឹកជញ្ជូនពូជស្រូវ ( សម្រាប់ព្រួស ) ការដឹកជញ្ជូនជីរដាក់ស្រែ ក៏ដូចជាការផលស្រូវក្រោយការច្រូតកាត់ ។ល។ កសិករមួយចំនួនបានធ្វើដំណើរលើចម្ងាយផ្លូវប្រហែល ១៥-១៨ គីឡូម៉ែត្រដើម្បីទៅដល់ទីផ្សារនៅទីរួមស្រុក។ ប៉ុន្តែជាមួយនឹងផ្លូវថ្មីមួយនៅតាមបណ្តោយប្រឡាយនោះកសិករអាចចំណាយពេលប្រហែល ៥-១០ នាទីពីផ្ទះទៅវាលស្រែ ហើយធ្វើដំណើរលើចម្ងាយផ្លូវប្រហែលតែ ៩គីឡូម៉ែត្រពីភូមិទៅទីផ្សារស្រុកស្វាយអន្ទរ។ ពីរឆ្នាំបន្ទាប់ពីគម្រោងនេះគេបានបញ្ចប់ គេសង្កេតឃើញផងដែរថាផ្ទះថ្មីមួយចំនួនត្រូវបានសាងសង់នៅតាមបណ្តោយផ្លូវនេះ។ ដូច្នេះកសិករអាចសន្សំការចំណាយនិងពេលវេលាលើការធ្វើដំណើរ និងអាចប្រើប្រាស់ពេលវេលានេះដើម្បីពិចារណានូវជម្រើសសកម្មភាពផ្សេងៗសម្រាប់ជីវភាពរស់នៅ ដូចជាការធ្វើសួនបន្លែគ្រួសារឬការចិញ្ចឹមសត្វដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពជីវភាពរស់នៅរបស់ពួកគេ។

លើសពីនេះទៀត ដោយយោងតាមការរបាយការណ៍ពីកសិករភាគច្រើន ត្រូវបានកត់សម្គាល់ថាដោយសារប្រឡាយមានជម្រៅជ្រៅ ធ្វើឱ្យប្រឡាយមានទឹកគ្រប់គ្រាន់ដែលជាការកែលម្អបរិស្ថាននិងអេកូឡូស៊ីបាន និងមានការកើនឡើងនូវបរិមាណត្រីក្នុងតំបន់ (រូបភាពទី ១៤) ។ មានកសិករប្រមាណជា ១០-២០ គ្រួសារអាចចាប់ត្រីជាមធ្យម ២



រូបភាព១៣: កសិករធ្វើដំណើរទៅកាន់ដីស្រែ និងទីផ្សារស្រុក ដោយប្រើប្រាស់ផ្លូវថ្មី

គីឡូក្រាមក្នុងមួយគ្រួសារក្នុងមួយថ្ងៃ។ ដូច្នេះគ្រួសារមួយអាចរកប្រាក់ចំណូលបានប្រហែល ៥ដុល្លារអាមេរិក / ថ្ងៃ (ប្រសិនបើ ១ គីឡូក្រាមត្រី = ២,៥ ដុល្លារអាមេរិក) ។ ការនេសាទអាចមានរយៈពេលពី ៤ ទៅ ៦ ខែក្នុងមួយឆ្នាំ (ពីខែមិថុនាដល់ខែវិច្ឆិកា)។ ដូច្នេះវាជាជម្រើសមុខរបរមួយទៀតដែលអាចបង្កើតប្រាក់ចំណូលកាន់តែច្រើនគឺ ប្រហែល ៦០០-៩០០ដុល្លារអាមេរិក ក្នុងមួយគ្រួសារក្នុងមួយឆ្នាំ។ ចំណូលសរុបពីការនេសាទនៅក្នុងប្រឡាយនេះអាចទទួលបានប្រមាណ១០០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំសម្រាប់១០-២០គ្រួសារ។ នេះបង្ហាញពីអត្ថប្រយោជន៍នៃគម្រោងនេះដោយប្រយោលតាមរយៈការជួសជុលប្រឡាយដែលបានប្រែពីការគំរាមកំហែងទៅជាឱកាសតាមរយៈឱ្យកសិករបង្កើនសមត្ថភាពបន្សាំដើម្បីទប់ទល់នឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅតាមរយៈការធ្វើនេសាទ។





រូបភាព ១៤: សកម្មភាពចាប់ត្រីក្នុងប្រឡាយនៅក្នុងខែធ្នូ ឆ្នាំ២០១៤

## ៣.៥ ការធ្វើអោយប្រសើរឡើងនូវវិធីសាស្ត្រដែលមានការចូលរួមចំរុះដើម្បីឱ្យមាននិរន្តរភាពរបស់គម្រោង

គម្រោងនេះមិនត្រឹមតែផ្តល់នូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម ដល់អ្នកទទួលផលពីគម្រោងប៉ុណ្ណោះទេ ប៉ុន្តែវាបានកសាងនូវកិច្ចសហការ និងការប្តេជ្ញាចិត្តរបស់ប្រជាជនក្នុងភូមិ អាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញនានា និងអង្គការមូលដ្ឋានដទៃទៀត។ តួនាទីរបស់ស្ត្រីនៅក្នុងជួរគណៈកម្មការគ្រប់គ្រង គឺជាកត្តាមួយដែលជំរុញឱ្យមានការចូលរួមទាំងបុរស និងស្ត្រីបានកើតឡើង។ គម្រោងនេះបានឱ្យស្ត្រីចូលរួមចាប់តាំងពីដំណាក់កាលរៀបចំគម្រោងរហូតដល់ការអនុវត្តគម្រោងដែលបានផ្តល់ផលប្រយោជន៍ទាំងបុរស និងស្ត្រី។ លើសពីនេះទៅទៀត គម្រោងបានផ្តល់ឱ្យស្ត្រីមានតួនាទីជាអ្នកដឹកនាំចាប់តាំងពីគម្រោងចាប់ផ្តើម ក្នុងនោះមានស្ត្រី២នាក់ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងចំណោមសមាជិក៦នាក់នៃគណៈកម្មការគ្រប់គ្រងធនាគារស្រូវ និងប្រឡាយ ។ ការចូលរួម ការតាំងចិត្ត និងការរៀនចំណេះដឹងពីគម្រោងបាននាំឱ្យមានការចូលរួមទាំងអស់គ្នា ក្នុងការបន្សាំនៅសហគមន៍លើការប្រែប្រួលអាកាសធាតុក្នុងតំបន់គោលដៅដូចដែលបានបង្ហាញនៅក្នុងការពិពណ៌នាខាងក្រោម(រូបភាព១៥)។ គណៈកម្មការគ្រប់គ្រងបានបំពេញតួនាទីគាំទ្រដល់សហគមន៍តាមរយៈសកម្មភាពស្ម័គ្រចិត្តជាច្រើន ដូចជាការចំណាយពេលវេលា ក្នុងការកៀរគរមូលនិធិក្នុងសហគមន៍ដើម្បីជួសជុល និងថែទាំប្រឡាយដែលបានស្តាររួច និងធានាថា ធនាគារស្រូវមានដំណើរការល្អ និងបានឆ្លើយតបនឹងតម្រូវការរបស់កសិករ។

ភាគច្រើននៃវិធីសាស្ត្រដែលនាំទៅរកភាពជោគជ័យ គឺការស្វែងរកកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ។ សហគមន៍ផ្ទាល់បានរួមបរិចាកដីកសិកម្ម និងកំលាំងពលកម្មដើម្បីស្តារប្រឡាយ សាងសង់ផ្លូវ ដាំកូនឈើ។ល។ សហគមន៍ជឿជាក់ថាការរួមចំណែករបស់ពួកគាត់នឹងនាំយកមកនូវលក្ខខណ្ឌដ៏ល្អសម្រាប់ជីវភាពរស់នៅ ឱ្យកាន់តែប្រសើរជាងមុន។ វិធីសាស្ត្រដែលមានការចូលរួមទាំងអស់គ្នាធ្វើឱ្យមាននិរន្តរភាពគម្រោង បានស្តែងឡើងតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម:

- មនុស្សចំនួន២៦៦ គ្រួសារ ដែលក្នុងនោះមានភូមិល្វា ២០០គ្រួសារ ភូមិសង្កែ ៣៣គ្រួសារ និងភូមិឧបមា ៣៣គ្រួសារ បានរួមចំណែកជាមួយមូលនិធិរបស់គំរោងនូវថវិកាផ្ទាល់ខ្លួនរបស់ពួកគេ ចំនួន ២២៨ដុល្លារអាមេរិក។







រូបភាព១៩: ការចូលរួមពីក្រុមបុរស និងស្ត្រីលើលទ្ធផលរបស់គម្រោង

- ផ្លូវ២ខ្សែប្រវែង ២៩៥ម៉ែត្រ ទទឹង ៣ម៉ែត្រ ដែលមានការចំណាយសរុបចំនួន ៩៦០ដុល្លារអាមេរិក ត្រូវបានចូលរួមចំណែកដោយគ្រួសារ១៧០ ដែលក្នុងមួយគ្រួសាររួមចំណែកថវិកាពី ២,៥០ ទៅ ៧,៥០ដុល្លារ។ លើសពីនេះទៅទៀត ៣ គ្រួសារដែលមានដីមានទីតាំងស្ថិតនៅក្នុងតំបន់គម្រោងចំងាយប្រហែល ៣០០ ម៉ែត្របានផ្តល់ ដីដល់គម្រោងសម្រាប់ការស្តារប្រឡាយទឹក។
- អង្គការDKC បានផ្តល់កូនឈើដោយមិនគិតថ្លៃចំនួន ១៣៥០ ដើម សម្រាប់សហគមន៍ដើម្បីដាំនៅលើខ្នងទំនប់ក្នុងគោលបំណងដើម្បីការពារការហូរច្រោះដី។ ដើម្បីដាំកូនឈើនេះ មនុស្ស ៣០០នាក់ រួមមានយុវជន សហគមន៍ គ្រូបង្រៀន អាជ្ញាធរមូលដ្ឋាន គណៈកម្មការគ្រប់គ្រង បានចូលរួមដាំកូនឈើនៅលើខ្នងទំនប់នេះ។
- ដីចំនួន ២៦ឡានបានចាក់បំពេញលើផ្លូវខ្នងទំនប់ខូចខាតប្រវែង ៣៥ម៉ែត្រនៅតាមបណ្តោយប្រឡាយដោយមានការគាំទ្រថវិកាពីកសិករ។
- ក្រុមប្រឹក្សាឃុំសង្កាត់បានប្រើប្រាស់ ថវិកាឃុំដើម្បីស្តារប្រឡាយ និងផ្លូវព្រោះយល់ថាវាជាគម្រោងអភិវឌ្ឍន៍របស់ឃុំ។

ការសម្រេចបានលទ្ធផលខាងលើ គឺដោយសារកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍កសិករប្រើប្រាស់ទឹក ដែលបានសហការជាមួយក្រុមប្រឹក្សាឃុំ ក្នុងការយកថវិកាមួយចំនួនពីខ្ទង់កសាងហេដ្ឋារចនាសម្ព័ន្ធរបស់មូលនិធិឃុំមកដាក់រួមបញ្ចូលជាមួយគម្រោងនេះ។ មន្ទីរធនធានទឹក និងឧតុនិយមខេត្តបានសហការជាមួយគណៈកម្មការគ្រប់គ្រងជួយសម្រួលដល់សហគមន៍ស្តីពីការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក និងចុងក្រោយសហគមន៍នេះត្រូវបានចុះឈ្មោះ និងបានទទួលស្គាល់ជាផ្លូវការដោយក្រុមប្រឹក្សាឃុំ។ គុណតម្លៃសមស្របបន្ថែមទៀតសម្រាប់គម្រោងនេះគឺភ្នាក់ងារដែលពាក់ព័ន្ធបានសហការជាមួយគ្នាទៅវិញទៅមកយ៉ាងល្អ និងបង្ហាញនូវជំនាញដែលសមស្របសម្រាប់វិស័យនីមួយៗដើម្បីការកែលម្អសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់គោលដៅ។

# ៤. បញ្ហាប្រឈមសំខាន់ៗ

ប្រឡាយដែលបានស្តារឡើងវិញអាចប្រើបានប្រហែលពីរទៅបីឆ្នាំ ហើយអាចផ្គត់ផ្គង់សម្រាប់តែដីស្រែដែលនៅជិតប្រឡាយប៉ុណ្ណោះ។ ទឹកប្រឡាយនេះអាចចែកចាយទៅដល់តែវាលស្រែក្នុងភូមិល្វាដែលវាស្ថិតនៅជិតប្រឡាយបំផុត រីឯវាលស្រែនៅភូមិផ្សេងទៀតមិនអាចទទួលទឹកសំរាប់ស្រោចស្រពបានទេ។ មានតែ១០% នៃអ្នកទទួលផលសរុបក្នុងភូមិគោលដៅទាំងអស់ អាចមានលទ្ធភាពទទួលទឹកសំរាប់ការស្រោចស្រពបាន។ យុទ្ធសាស្ត្រនេះអាចជួយសហគមន៍ក្នុងការបន្សុាំទៅនឹងការស្ថានភាពការប្រែប្រួលអាកាសធាតុ នៅពេលដែលមានការអូសបន្លាយគ្រោះរាំងស្ងួតនៅក្នុងរដូវវស្សា ។សម្រាប់យុទ្ធសាស្ត្ររយៈពេលវែង, ប្រឡាយស៊ីម៉ង់ត៍គឺជាវិធីសាស្ត្រដ៏ល្អបំផុតសម្រាប់ការបន្សុាំ ទោះជាយ៉ាងណាវាមានតម្លៃខ្ពស់។

ក្នុងករណីកសិករត្រូវការទឹកបន្ថែមទៀតពីប្រឡាយរបស់ស្រុក ដើម្បីបង្កើនការដាំដុះ វាតម្រូវឱ្យមានការបូមទឹក ។ ដូច្នេះវាជាការលំបាកមួយផ្សេងទៀតសម្រាប់កសិករក្នុងការចំណាយប្រាក់កាន់តែច្រើនលើផលិតកម្មស្រូវ។ ការស្តារឡើងវិញនៃប្រឡាយនេះមិនបានជួយដល់កសិករដែលមានដីស្រែចំការនៅឆ្ងាយពីប្រឡាយ(៥០០ម៉ែត្រ)។ វាជាការសំខាន់ដើម្បីកសាងប្រឡាយរងដែលអាចនាំទឹកបន្ថែមទៀតដើម្បីជួយដល់វាលស្រែផ្នែកខាងក្រោមដែលស្ថិតនៅឆ្ងាយពីប្រឡាយមេ។ លើសពីនេះទៀត ប្រឡាយនេះគឺពឹងផ្អែកទាំងស្រុង ពីទឹកភ្លៀង និងដែលភាគច្រើនទឹកហូរមកពីវាលស្រែតំបន់ខ្ពស់នៅផ្នែកខាងលើនៃតំបន់គម្រោង ដូច្នេះប្រសិនបើមិនមានភ្លៀងធ្លាក់ទេប្រឡាយនេះគឺទំនងជានឹងមិនមានទឹកទេ។ ម្យ៉ាងវិញទៀតការគ្រប់គ្រងការពង្រីកស្រែដើមរដូវដោយគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក គឺមានបញ្ហាប្រឈមប្រសិនបើតំបន់ស្រោចស្រពត្រូវបានបង្កើនច្រើនជាង២០ហិកតានៅចុងរដូវវស្សា។ ដូច្នេះ វាទំនងជាមានជម្លោះនៃការចែករំលែកទឹកដែលនឹងកើតឡើងក្តៅគគុក។

គម្រោងមានរយៈពេលខ្លី (តែ១ ឆ្នាំ) គឺជាឧបសគ្គមួយទៀតសម្រាប់អ្នកទទួលផលក្នុងតំបន់គោលដៅ។ គណៈកម្មការគ្រប់គ្រងធនាគារស្រូវ និងប្រឡាយក៏បានជួបការលំបាកក្នុងការបន្សុាំ និងឯកភាពជ្រាភាពចំពោះការជ្រើសរើសវិធីសាស្ត្រសម្រាប់ការដាំដុះ និងការប្រើប្រាស់ និងថែទាំប្រឡាយអោយមាននិរន្តរភាព។ គណៈកម្មការគ្រប់គ្រងធនាគារស្រូវ និងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកមានភាពទន់ខ្សោយក្នុងការគ្រប់គ្រងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ជាពិសេសគឺនៅតែមានកម្រិត ក្នុងការប្រមូលសេវាប្រើប្រាស់ទឹកដើម្បីធ្វើការថែទាំប្រឡាយ និងការផ្តល់គោលការណ៍ណែនាំច្បាស់លាស់ដល់កសិករពីរបៀបជ្រើសពូជស្រូវល្អដើម្បីសងត្រឡប់ទៅធនាគារស្រូវវិញ ព្រោះថាវាអាចប៉ះពាល់ដល់គុណភាពនៃពូជស្រូវប្រើប្រាស់សម្រាប់អ្នកខ្ចីក្រោយៗក្នុងរដូវកាលបន្ទាប់។ ការបណ្តុះបណ្តាលលើ ប.វ.ស គឺមិនសមទៅនឹងតម្រូវការរបស់ប្រជាជនខណៈដែលពួកគេមានកម្លាំងពលកម្មតិច និងដីស្រែមានទំហំធំ ហើយជាប្រភេទស្រែជំរៅជាហេតុនាំអោយ ៥០% នៃកសិករដែលបានទទួលការបណ្តុះបណ្តាលមិនអាចយកមកអនុវត្តបាន។

# ៥. ការអនុវត្តល្អ និងមេរៀនសម្រាប់ការរៀនសូត្រ

ទោះបីជាគម្រោងនេះបានដំណើរការសម្រាប់តែមួយឆ្នាំក៏ដោយ ក៏គម្រោងនេះមានសមិទ្ធិផលដ៏សំខាន់ជាច្រើន និងការអនុវត្តដ៏ល្អបានកើតឡើងនៅក្នុងតំបន់គោលដៅ។ មានការសហការ និងគាំទ្រយ៉ាងល្អពីមន្ទីរធនធានទឹក និងឧតុនិយម(PDOWRAM) ក៏ដូចជាអាជ្ញាធរភូមិ ឃុំ ជាឱកាសល្អឱ្យមានការពិភាក្សារវាងអ្នកផ្តល់សេវាកម្មបច្ចេកទេស និងអាជ្ញាធរមូលដ្ឋានបានជួបពិភាក្សាជាមួយសហគមន៍ដើម្បីដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងផលប៉ះពាល់ពីការស្តារប្រឡាយ និងការប្រែប្រួលអាកាសធាតុ និងលើកឡើងពីតម្រូវការរបស់ប្រជាជន ដើម្បីធ្វើអោយប្រជាជនក្នុងតំបន់គោលដៅគម្រោងមានជីវភាពរស់នៅប្រសើរឡើង។ នេះជាវិធីសាស្ត្រដ៏ល្អមួយដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធជាពិសេសអ្នកភូមិខ្លួនឯងមានឱកាសក្នុងការបង្កើតសកម្មភាពគម្រោងដោយមានកិច្ចសហការជាមួយម្ចាស់គម្រោង និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់។ ជាលទ្ធផល សហគមន៍ត្រូវបានគេផ្តល់អំណាចក្នុងការទទួលយកភាពជាម្ចាស់លើការប្រើប្រាស់ និងការថែទាំប្រឡាយ ក៏ដូចជាការអនុវត្តការងារកសិកម្ម។ គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកនេះនៅតែដំណើរការបន្ទាប់ពីការបញ្ចប់នៃគម្រោង បើទោះបីជាសមត្ថភាពពួកគាត់ក្នុងការគ្រប់គ្រងប្រឡាយនៅមានកម្រិតក៏ដោយ តែពួកគាត់ត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាឃុំ និងបានបង្កើតឡើងជាផ្លូវការដោយមានការគាំទ្រពីមន្ទីរធនធានទឹកនិងឧតុនិយម។ កសិករបានយល់ដឹងអំពីសារៈសំខាន់នៃបច្ចេកទេសកសិកម្ម (ខ្លះអនុវត្ត ប.វ.ស. និងមួយចំនួនបានផ្លាស់ប្តូរពីការអនុវត្ត ប.វ.ស. ទៅការដាំដោយគ្រាប់ដោយប្រើប្រាស់ឧបករណ៍ drum seeder ដោយផ្អែកលើលក្ខខណ្ឌ ដីស្រែ) និងមានបំណងក្នុងការអនុវត្តវិធីសាស្ត្រនេះសម្រាប់ការធ្វើស្រែ ដែលអាចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ និងការកាត់ បន្ថយការប្រើថ្នាំសំលាប់សត្វល្អិត។ កសិករភាគច្រើនបានរួមចំណែក ជាសម្ភារៈ និងកំលាំងពលកម្មដើម្បីគាំទ្រការស្តារប្រឡាយ ការសាងសង់ផ្លូវ និងការដាំដើមឈើ។ល។

មេរៀនដ៏សំខាន់សម្រាប់ការរៀនសូត្រពីគម្រោងនេះគឺសហគមន៍កសិករអាចប្រែក្លាយការគំរាមកំហែងឱ្យទៅជាឱកាសល្អ តាមរយៈការស្តារប្រឡាយដែលអាចមានលទ្ធភាពរក្សាទឹកទុក និងការប្រមូលទឹកពីតំបន់ខ្ពស់ផ្នែកខាងលើ នៃប្រឡាយ ដើម្បីផលិតកម្មស្រូវ។ មិនត្រឹមតែប៉ុណ្ណោះទេ ប្រឡាយនេះថែមទាំងអាចបង្កើនផលត្រីដែលជាជំរើសសកម្មភាពចិញ្ចឹមជីវិតមួយបន្ថែមទៀតដល់កសិករក្នុងតំបន់។

វាក៏ជាការសំខាន់ផងដែរសម្រាប់ការរៀនសូត្រលើការងារគណនេយ្យភាព និងតម្លាភាពនៅក្នុងដំណើរការដេញថ្លៃសម្រាប់ការស្តារ ប្រឡាយដែលអាចសន្សំសំចៃការចំណាយថវិកាបស់គម្រោងនេះ និងអាចធ្វើការគ្រប់គ្រងរាល់បញ្ហានៅក្នុងដំណើរការដេញថ្លៃ។ ម្យ៉ាងទៀត ថវិកាដេញថ្លៃនេះ អាចសម្រេចបានលើសពីគោលដៅដែលជាតម្រូវការរបស់គម្រោងនេះ។ លើសពីនេះទៀត ជាមួយនឹងការផ្តួចផ្តើមពីគម្រោងកិច្ចសហប្រតិបត្តិការដ៏ល្អក្នុងចំណោមសមាគមន៍ កសិករ អ្នកម៉ៅការ អាជ្ញាធរមូលដ្ឋាន រួមមានក្រុមប្រឹក្សាឃុំ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត អង្គការ DKC និងដៃគូដទៃទៀតត្រូវបានកើតមានឡើង និងជាពិសេសការរួមបដិភាគថវិកាឃុំ ដើម្បីធ្វើឱ្យអាជ្ញាធរ និងក្រុមទទួលផលគម្រោងមានភាពជាម្ចាស់ ក្នុងការគ្រប់គ្រងសមិទ្ធិផលគម្រោងប្រកបដោយនិរន្តរភាព។ ដូចគ្នានេះផងដែរ វាជាចំណុចចាប់ផ្តើមដ៏ល្អបំផុតសម្រាប់ការកសាងភាពជាម្ចាស់របស់សហគមន៍ និងអាជ្ញាធរមូលដ្ឋានក៏ដូចជាការកសាងវប្បធម៌នៃការសហការគ្នាទៅវិញទៅមកដើម្បីចាប់ដៃគ្នាក្នុងការជួយកែលម្អជីវភាពរស់នៅរបស់សហគមន៍ក្នុងតំបន់។

មេរៀនសម្រាប់ការរៀនសូត្រដ៏ល្អមួយផ្សេងទៀតដែលគួរត្រូវអនុវត្តសម្រាប់គម្រោងបន្ទាប់គឺ ការអនុវត្តយកស្រូវបន្ទាប់ពីការច្រូតកាត់ជំនួសឱ្យការយកសាច់ប្រាក់ ដែលជាសេវាថ្លៃទឹក។ វិធីសាស្ត្រនេះអាចធ្វើឱ្យកសិករមានអារម្មណ៍ថាមានភាពកក់ក្តៅជាង ការបង់សាច់ប្រាក់ដោយផ្ទាល់លើការប្រើប្រាស់ទឹកពីប្រឡាយ។ ទោះយ៉ាងណាក៏ដោយ នេះអាចជាការប្រឈមមួយសម្រាប់គណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកលើប្រើប្រាស់ និងការថែទាំប្រឡាយនៅពេលដែលកសិករមិនអាចទទួលបានទិន្នផលស្រូវគ្រប់គ្រាន់បន្ទាប់ពីការប្រមូលផលបើប្រៀបធៀបទៅនឹងការចំណាយសរុបរបស់ពួកគេ លើការធ្វើស្រែ។

ការប្រើឧបករណ៍ VRA នេះ មិនត្រឹមតែសម្រាប់សហគមន៍ខ្លួនឯងនោះទេ ប៉ុន្តែវាក៏សម្រាប់អាជ្ញាធរមូលដ្ឋានជាពិសេសក្រុមប្រឹក្សាឃុំសង្កាត់ ក៏អាចកំណត់ពីបញ្ហាប្រឈមចម្បងៗរបស់ប្រជាពលរដ្ឋ និងកំណត់អាទិភាពចាំបាច់ដែលត្រូវអនុវត្តនៅក្នុងតំបន់របស់ពួកគេក្នុងគោលបំណងដើម្បីផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចសង្គមសម្រាប់ជីវភាពអ្នកភូមិ។ ដូចគ្នានេះផងដែរឧបករណ៍នេះអាចតាស់កកាយជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីពិចារណាអំពីវិធីសាស្ត្រ ដោយមានការចូលរួមតាមរយៈការពិភាក្សាគ្នាទៅវិញទៅមក ដើម្បីរកវិធីដោះស្រាយបញ្ហាជាមួយគ្នា ដែលសកម្មភាពនេះគឺខុសគ្នាពីវប្បធម៌នៃភាពស្ងៀមស្ងាត់របស់ប្រជាជនកម្ពុជា។ ដូច្នេះ ការអនុវត្តរបស់ CRID ក្នុងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍គោលដៅ និងភាគីពាក់ព័ន្ធនានាបានជំរុញឱ្យ ឃុំសាំងឃ្វាងធ្វើសមាហរណកម្មការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# ៦. សន្និដ្ឋាន និងអនុសាសន៍

ការជ្រើសរើសការស្តារប្រឡាយរួមមាន ប្រឡាយ២ខ្សែ និងទំនប់នៅតាមបណ្តោយប្រឡាយទទួលបានជោគជ័យក្នុងការប្រមូលទឹក និងការគ្រប់គ្រងទឹកក្នុងប្រឡាយ។ សារសំខាន់លើសនេះទៀត តំបន់ភាគខាងលើ និងខាងក្រោមនៃប្រឡាយ និងទំនប់អាចរក្សាសំណើមដីបានរយៈពេលយូរនៅក្នុងអំឡុងពេលនៃការអូសបន្លាយគ្រោះរាំងស្ងួតនៅរដូវវស្សា និងអាចបន្សាំទៅនឹង ការអូសបន្លាយគ្រោះរាំងស្ងួតនៅក្នុងរដូវវស្សាផងដែរ។ លើសពីនេះទៅទៀត ទំនប់តាមបណ្តោយប្រឡាយបានក្លាយជាផ្លូវលំដ៏សំខាន់មួយនៅក្នុងតំបន់គោលដៅដើម្បីជួយសម្រួលការធ្វើដំណើរទៅកាន់វាលស្រែ និងជាផ្លូវគមនាគមន៍តភ្ជាប់ទៅកាន់ឃុំ និងស្រុកនៅក្បែរទីនោះផងដែរ។ លទ្ធផលនេះ អាចកាត់បន្ថយ ពេលវេលា និងការចំណាយសម្រាប់ការដឹកជញ្ជូនសម្ភារៈកសិកម្ម ទៅស្រែ និងការធ្វើដំណើរទៅខាងក្រៅឃុំ។ លទ្ធផលដែលមិនរំពឹងថានឹងកើតឡើងនោះគឺបានកើតឡើងបន្ទាប់ពី ប្រឡាយត្រូវបានស្តារឡើងវិញ ដូចជា ការកើនឡើងនៃបរិមាណត្រីនៅក្នុងប្រឡាយ និងក្នុងស្រែការដាំដំណាំផ្សេងទៀត (ឪឡឹក ឬត្រសក់) និងការតាំងលំនៅដ្ឋានថ្មីរបស់អ្នកភូមិ។ សហគមន៍អាចបង្កើនប្រាក់ចំណូល និងដកខ្លួនចេញពីបំណុលរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ពីលទ្ធផលទាំងនេះ គ្រួសារខ្លះអាចបញ្ជូនកូនទៅបន្តការសិក្សានៅសាកលវិទ្យាល័យ នៅទីក្រុងភ្នំពេញ។

សកម្មភាពអន្តរាគមន៍របស់គម្រោងទាំងអស់បានឆ្លើយតបទៅនឹងវិធានការបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍ ក្នុងការធានាសន្តិសុខស្បៀង តាមរយៈការប្រមូល និងគ្រប់គ្រងទឹកនៅនឹងកន្លែងដើម្បីធានាទឹកគ្រប់គ្រាន់សម្រាប់ការធ្វើស្រែនៅក្នុងរដូវវស្សា (ដែលកន្លងមកកសិករតែងតែជួបប្រទះញឹកញាប់ជាមួយនឹងការខ្វះខាត ទឹកអំឡុងពេលនៃការអូសបន្លាយគ្រោះរាំង ស្ងួត នៅក្នុងរដូវវស្សា) និងដំហានបន្តក្នុងការ បង្កើនការធ្វើស្រែ ១ដង ទៅ ៣ដងសម្រាប់អ្នកដែលមានស្រែជាប់នឹងប្រឡាយ, ធ្វើឱ្យប្រសើរឡើងនូវសកម្មភាពនេសាទ ការបង្កើនពូជស្រូវសម្រាប់រក្សាទុកក្នុងធនាគារស្រូវ ពង្រីកចំនួនទឹកប្រាក់នៃមូលនិធិភូមិតាមរយៈយន្តការក្រុមសន្សំ និងផ្លូវងាយស្រួលទៅវាលស្រែ និងទីផ្សារ។

តាមរយៈការកសាងសមត្ថភាពដែលផ្តល់ដោយគម្រោង ទាំងសហគមន៍ និងទាំងសមាជិកក្រុមប្រឹក្សាឃុំ រួមមានការប្រែប្រួលអាកាសធាតុ ការអប់រំផ្សព្វផ្សាយ និងវិធីសាស្ត្រគ្រប់គ្រងដំណើរការធនាគារស្រូវ និងប្រើប្រាស់ប្រឡាយ ការថែទាំ ត្រូវបានពង្រឹង និងបង្កើនភាពជាម្ចាស់ការ ដើម្បីជំរុញឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅក្នុងតំបន់របស់ពួកគេ។ វិធីសាស្ត្របន្សាំនេះ បានជួយកសិករឱ្យមានទំនុកចិត្តកាន់តែខ្លាំង ហើយបានផ្លាស់ប្តូរទំលាប់នៃការធ្វើស្រែដូចជាការធ្វើស្រែកើនឡើងរហូតដល់ទៅ ៣ដងក្នុងមួយឆ្នាំ និងដំណាំផ្សេងទៀតដូចជាឪឡឹក ត្រសក់ និងបន្លែជាច្រើនទៀតនៅក្នុងតំបន់នេះ ខណៈដែលពីមុន ពួកគេមានការអស់សង្ឃឹមក្នុងការធ្វើស្រែសូម្បីតែ ១ដងក្នុងមួយឆ្នាំ ដោយសារតែមិនមានការកែលម្អការគ្រប់គ្រងទឹក ការប្រមូលទឹកនៅនឹងកន្លែង។លើសពីនេះទៀត ផលនេសាទមានការកើនឡើងដោយសារតែមានបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីដ៏ល្អក្នុងប្រឡាយ និងដោយសារមានប្រភពទឹកហូរមកពីវាលស្រែ ផ្នែកខាងលើនៃប្រឡាយ។ វាបានក្លាយទៅជាជម្រើសនៃការរកប្រាក់ចំណូលប្រចាំថ្ងៃបន្ថែមសម្រាប់សហគមន៍ក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។

ចំណុចសំខាន់បំផុតគឺ ការកសាងការសហការគ្នាទៅវិញទៅមក និងវិធីសាស្ត្រដោយមានការការចូលរួមរវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ជាពិសេសក្រុមប្រឹក្សាឃុំសង្កាត់ មន្ទីរជំនាញពាក់ព័ន្ធដើម្បីពិចារណាសកម្មភាពអភិវឌ្ឍនាពេលអនាគតនៅក្នុងតំបន់នេះ ដោយប្រើប្រាស់មូលនិធិឃុំដែលស្ថិតនៅក្រោមការគាំទ្រជាសម្ភារៈ និងកំលាំងពលកម្មពីអ្នកភូមិ។

អនុសាសន៍មួយចំនួនដើម្បីធ្វើឱ្យប្រសើរឡើងនាពេលអនាគតនៃគម្រោងស្រដៀងគ្នា ឬការបន្តនៃគម្រោងដែលមានស្រាប់ត្រូវបានផ្តល់ឱ្យដូចខាងក្រោមៈ

- SMART (ជាក់លាក់ អាចវាស់វែងបាន អាចសំរេចបាន ពិតប្រាកដ និងពេលវេលាជាក់លាក់) របស់គម្រោងគឺជាកត្តាគន្លឹះក្នុងការជំរុញឱ្យសំរេចបាននូវសមិទ្ធិផល ដែលការអនុវត្តគម្រោងមានរយៈពេលខ្លី។
- ពិចារណាការពន្យារយៈពេលអនុវត្តគម្រោងពី ១ឆ្នាំ ទៅជា ២ឆ្នាំ គឺមានសារៈសំខាន់ទាំងបុគ្គលិកគម្រោង ទាំងអ្នកទទួលផល (គណៈកម្មការគ្រប់គ្រងប្រឡាយ និងគណៈកម្មការគ្រប់គ្រងធនាគារស្រូវ អាជ្ញាធរមូលដ្ឋាន និងកសិករ) អាចពង្រឹងសមត្ថភាពរបស់ពួកគាត់ និងអាចបន្សាំទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុក្នុងតំបន់។
- ជាការសំខាន់ណាស់ក្នុងការយល់ដឹងពីប្រភពទឹក តម្រូវការទឹកស្រោចស្រពសម្រាប់ដំណាំស្រូវ និងដីដែលមានសក្តានុពលស្រោចស្រពសម្រាប់ការលើកគម្រោងជាកសាស្ត្រ ដើម្បីកំណត់ទំហំប្រឡាយ និងរៀបចំផែនការប្រើប្រាស់ធនធានទឹក ពិសេសការពង្រឹងសមត្ថភាពរបស់គណៈកម្មការសហគមន៍កសិករ ប្រើប្រាស់ទឹកក្នុងការជំរុញឱ្យមានការទទួលខុសត្រូវកាន់តែច្រើន និងការអនុវត្តតួនាទីឱ្យបានល្អរបស់ឃុំទៅលើដំណើរការប្រើប្រាស់ និងថែទាំប្រឡាយ។ ការបែងចែកទឹកស្រោចស្រពត្រូវតែមានផែនការច្បាស់លាស់ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍។
- គម្រោងនឹងទទួលបានជោគជ័យបន្ថែមទៀត ប្រសិនបើមានលទ្ធភាពក្នុងការជីកប្រឡាយរងដើម្បីនាំយកទឹកពីបឹងនេះ នៅតំបន់ខ្សែទឹកខាងលើ និងជីកប្រឡាយរងមួយផ្សេងទៀត ដើម្បីជួយដល់កសិករដែលមានដីស្រែស្ថិតនៅផ្នែកខាងក្រោម ឆ្ងាយពីប្រឡាយមេនេះ។
- តំបន់នេះបានប្រឈមមុខជាមួយនឹងការធ្វើចំណាកស្រុកទៅកាន់តំបន់ទីក្រុង ឬប្រទេសក្រៅដែលអាចប៉ះពាល់ដល់តម្រូវការកម្លាំងពលកម្មសម្រាប់ការងារកសិកម្ម។ ដូច្នេះការរក្សាយុវជនជំនាន់ក្រោយ និងការផ្តល់ឱកាសដល់ពួកគេកាន់តែច្រើនគឺជាយន្តការសំខាន់មួយទៀតត្រូវពិចារណា។ នៅពេលដែលពួកគេអាចទទួលបានប្រាក់ចំណូលកាន់តែច្រើននៅក្នុងប្រទេសពីការធ្វើកសិកម្ម ពួកគេនឹងរស់នៅក្នុងប្រទេសជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ។

# ៧. ឯកសារយោង


1. គេហទំព័រ http://en.wikipedia.org/wiki/Prey_Veng_Province បានទៅយកនៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៤
2. សលាកបត្រព័ត៌មានគម្រោង CCCA ខែសីហាឆ្នាំ ២០១២:គំនិតផ្តួចផ្តើមដើម្បីដោះស្រាយរួមគ្នាលើការប្រែប្រួលអាកាសធាតុ-ព្រៃវែង (TACCI-PV)
3. Yusuf A & Francisco H. 2009.ផែនទីភាពងាយរងគ្រោះនៃការប្រែប្រួលកាសធាតុសម្រាប់អាគ្នេយ៍ សេដ្ឋកិច្ចអាស៊ី និងកម្មវិធីបរិស្ថានប្រចាំតំបន់អាស៊ីអាគ្នេយ៍ (EEPSEA): ប្រទេសសិង្ហបុរី
4. NGOF. 2014. អភិរក្សកសិកម្មនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃភាពសម្បូរបែបធញ្ញជាតិតាមរយៈការបង្កាត់ពូជរបស់រុក្ខជាតិដែលមានការចូលរួមនិងការធានាប្រព័ន្ធពូជក្នុងស្រុកនៅក្នុងបណ្តាខេត្តដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា:
5. របាយការណ៍ឃុំ ឆ្នាំ ២០១១ ទិន្នន័យប្រជាជនឃុំសៀងឃ្វាង
6. សៀវភៅទិន្នន័យ និងស្ថានភាពឃុំសៀងឃ្វាង ឆ្នាំ ២០១១
7. CRID. 2011. សំណើគម្រោងពេញលេញរបស់ អង្គការ CRID ស្តីពី"ការពង្រឹងសមត្ថភាពរបស់សហគមន៍ដើម្បីបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុក្នុងឃុំ សៀងឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង "២០១១
8. ទិន្នន័យឃុំសៀងឃ្វាង ឆ្នាំ ២០១១

Empowered lives.
Resilient nations.


**កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ**

អគារលេខ ៥៣ វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង ក្រុងភ្នំពេញ
ព្រះរាជាណាចក្រ ប្រអប់សំបុត្រលេខ៖ ៨៧៧
ទូរស័ព្ទ៖ (855) 23 216 167 or 214 371
ទូរសារ៖ (855) 23 216 257 or 721 042
អ៊ីម៉ែល៖ registry.kh@undp.org
www.kh.undp.org